ក្រុមសៀវភៅការរុករកឃើញ®

# ក្តីសង្ឃឹម

## ការជ្រើសរើសយកជំនឿ ជាជាងរើសយកការភ័យខ្លាច



និពន្ធដោយ លោកប៊ីល ក្រោដឺរ( Bill Crowder )



*សេចក្តីផ្តើម*

## ក្តីសង្ឃឹម
## ការជ្រើសរើសជំនឿ ជាជាងការភ័យខ្លាច

សូម្បីតែអ្នកដើរតាមព្រះគ្រីស្ទ ដែលមានការប្តូរផ្តាច់បំផុត ក៏ងាយនឹងជួបពេល ឬរដូវកាលនៃភាពអស់សង្ឃឹម។ ជាក់ស្តែងសាវ័កប៉ុលក៏ធ្លាប់បាននិយាយ អំពីបន្ទុកដែលធ្ងន់ក្រៃលែង ដែលបានធ្វើឲ្យគាត់ និងក្រុមការងារគាត់អស់សង្ឃឹមនឹងនៅរស់(២កូរិនថូស ១:៨)។ ប៉ុន្តែ គាត់បានពន្យល់ថាការនេះបានកើតឡើង គឺដើម្បីឲ្យគាត់បានរៀនពឹងផ្អែកទៅលើព្រះជាម្ចាស់ជាជាងពឹងផ្អែកខ្លួនឯង(ខ.៩)។

ការស្វែងរកក្តីសង្ឃឹម ក្នុងពេលអស់សង្ឃឹម គឺពិតជាចាំបាច់ណាស់។ ប៉ុន្តែ ដូចដែលលោកប៊ីល ក្រោឌ័រ(Bill Crowder)ដែលជាគ្រូបង្រៀនព្រះគម្ពីរ នៃព័ន្ធកិច្ចនំម៉ាណា បានចង្អុលបង្ហាញ ក្នុងទំព័រសៀវភៅនេះ មានភាពអស់សង្ឃឹមមួយប្រភេទ ដែលពិតជាអាចប្រែក្លាយជាក្តីសង្ឃឹមពិតប្រាកដ សម្រាប់ថ្ងៃថ្មី ផ្លូវថ្មី និងក្តីសង្ឃឹម ដែលស្ថិតស្ថេរជារៀងរហូត។

Mart DeHaan

# មាតិកា

*ទីមួយ*

**ក្តីសង្ឃឹម សម្រាប់ពេលអស់សង្ឃឹម....................................... 5**

*ទី២*

**អត្ថន័យនៃក្តីសង្ឃឹម........................................................ 9**

*ទីបី*

**ប្រភពនៃក្តីសង្ឃឹម .......................................................15**

*ទី៤*

**ក្តីសង្ឃឹម សម្រាប់លោកិយ ដែលគ្មានសង្ឃឹម...................21**

*ទី៥*

**មូលដ្ឋានគ្រឹះនៃក្តីសង្ឃឹម..................................................24**

*ទី៦*

**ក្តីសង្ឃឹមដ៏ស្ថិតស្ថេរ ........................................................28**

MANAGING EDITOR: J. R. Hudberg
EDITOR: Tim Gustafson
COVER IMAGE: ©iStock.com/Luismmolina
COVER DESIGN: Stan Myers
INTERIOR DESIGN: Steve Gier
Interior Images: ( p.1 ) ©iStock.com/Luismmolina; ( p.5 ) Chris1961 via FreeImages.com; ( p.9 ) Francis Mac Donald via MorgueFile.com; ( p.15 ) Constantin Jurcut via RGBStock.com; ( p.21 ) Carlos Paes via FreeImages.com; ( p.25 ) Tory Byrne via FreeImages.com; ( p.29 ) Ryan McGuire via Pixabay.com.
All Scripture quotations, unless otherwise indicated, are taken from the NEW AMERICAN STANDARD BIBLE®, Copyright © 1960, 1962, 1963, 1968, 1971, 1972, 1973, 1975, 1977, 1995 by The Lockman Foundation. Used by permission.
© 2011, 2015 Our Daily Bread Ministries, Grand Rapids, MI
All rights reserved.



*ទីមួយ*

## ក្ដីសង្ឃឹម សម្រាប់ពេលអស់សង្ឃឹម

**នៅពេលមួយនោះ** ពួកអ៊ីស្រាអែលមានពេញដោយការភ័យខ្លាចនៅក្នុងចិត្ត។ នៅពីមុខពួកគេ មានទឹកសមុទ្រក្រហម ដែលហាក់ដូចជាគ្មាននរណាអាចឆ្លងកាត់បាន។ នៅពីក្រោយពួកគេ មានកងទ័ពរទេះចម្បាំងរបស់ស្ដេចផារ៉ោនកំពុងតែដេញតាមពួកគេ ដោយសម្លេងសន្ធឹកដូចផ្គរលាន់។ ពួកគេក៏បានរអ៊ូរទាំចំពោះលោកម៉ូសេ ដោយភាពតក់ស្លុត់ ដោយការចោទប្រកាន់ថា "តើដោយព្រោះតែគ្មានផ្នូរនៅស្រុកអេស៊ីព្ទឬអី បានជាអ្នកនាំយើងរាល់គ្នាមក ត្រូវឲ្យស្លាប់នៅទីរហោស្ថាននេះដូច្នេះ?"(និក្ខមនំ ១៤:១០)។

ពេលនោះជាពេលដែលពួកគេអស់សង្ឃឹម។ ពួកគេទើបតែមានសេរីភាពបានតែមួយរយៈពេល ឥឡូវនេះ ពួកគេកំពុងតែប្រឈមមុខដាក់ការវិលត្រឡប់ដ៏គួរឲ្យភ័យខ្លាច ទៅរកភាពជាទាសករ នៅនគរអេស៊ីព្ទវិញ ឬត្រូវស្លាប់ដោយការលង់ទឹកក្នុងសមុទ្រក្រហម។ តែអរគុណព្រះអង្គ ដែលបានសង្គ្រោះពួកគេក្នុងភាពទាល់ច្រកពេលនោះ។

សព្វថ្ងៃនេះ យើងក៏កំពុងតែរស់នៅក្នុងពេលដែលមនុស្សជាច្រើនកំពុងជួបភាពអស់សង្ឃឹម។ យើងប្រហែលជាមិនកំពុងតែជាប់ខ្លួននៅក្នុងភាពទាល់ច្រក ដោយត្រូវសម្រេចចិត្តប្រឈមមុខដាក់កងទ័ពដ៏ខ្លាំងពូកែ ឬត្រូវជ្រើសរើសយកការសម្លាប់ខ្លួននៅក្នុងទឹកដូចពួកអ៊ីស្រាអែលនោះឡើយ ប៉ុន្តែ ជីវិតរបស់យើងតែងតែជួបបញ្ហាប្រឈមឥតឈប់ឈរ ដែលបានធ្វើឲ្យយើងមានអារម្មណ៍ថា យើងកំពុងតែទាល់ច្រក។ បុរសស្ត្រីដែលបានបំពេញការងាររបស់ខ្លួន យ៉ាងមានប្រសិទ្ធភាព អស់រយៈពេលជា

ច្រើនឆ្នាំ កំពុងតែប្រឈមមុខនឹងការបាត់បង់ការងារធ្វើ និងភាពគ្មានជម្រើស។ យុវជនជាច្រើនកំពុងតែប្រឈមមុខជាក់អនាគត ដែលមិនមានឱកាស ដូចឪពុកម្តាយ និងជីដូនជីតារបស់ខ្លួន ព្រោះការអប់រំរបស់ពួកគេហាក់ដូចជាគ្មានប្រយោជន៍ ពេលដែលពួកគេមិនអាចរកការងារធ្វើបាន។ នៅក្នុងតំបន់ជាច្រើន ក្នុងពិភពលោកនេះ គ្រោះថ្នាក់ជាច្រើនបានកើតឡើង ដោយសារអំពើភារវកម្ម និងភាពក្រីក្រ។ គ្រោះធម្មជាតិបាននាំឲ្យមានការខាតបង់មិនអាចពិពណ៌នាបាន មកលើសហគមន៍ និងតំបន់ទាំងមូល។

ស្ថិតក្នុងពេលដ៏អស់សង្ឃឹមបែបនេះ មានតែក្តីសង្ឃឹមទេ ដែលជាដំណោះស្រាយដ៏មានប្រសិទ្ធភាព។ ប៉ុន្តែ ក្តីសង្ឃឹមនោះមិនមែនជាការប៉ងប្រាថ្នា ឬសន្យាខ្យល់ មិនអាចទុកចិត្តបាន និងជាការគិតបែបសប្បាយៗ ដែលយើងច្រើនតែធ្វើពេលដែលយើងចង់និយាយ តែមិនដឹងនិយាយអំពីអ្វី។ យើងត្រូវការក្តីសង្ឃឹមពិតប្រាកដ ដែលមានន័យ និងមានអំណាច។ ក្តីសង្ឃឹមដែលជាប់ជាមួយនឹងការសន្យា និងមានមូលដ្ឋានពិតប្រាកដ។

គ្មាននរណាម្នាក់ដែលស៊ាំនឹងបញ្ហានោះឡើយ។ យើងរាល់គ្នា សុទ្ធតែជួបការគំរាមកំហែង ដែលមានដូចជា ការបាត់បង់របេចិញ្ចឹមជីវិត ជម្ងឺដែលគំរាមកំហែងជីវិត គ្រោះធម្មជាតិ ទំនាក់ទំនងដែលប្រេះឆាជាដើម។ ប៉ុន្តែ ដែលសំខាន់នោះ តើយើងនឹងឆ្លើយតបដូចម្តេច ចំពោះពេលដែលអស់សង្ឃឹមនោះ។ តើអ្នកដើរតាមព្រះយេស៊ូវបានឆ្លើយតបដូចម្តេចខ្លះ? តើការឆ្លើយតបរបស់យើង បាននិយាយអ្វីខ្លះអំពីជំនឿរបស់យើង ទៅកាន់អ្នកកំពុងសង្កេតមើលយើង? តើពួកគេមើលឃើញយើងកំពុងតែឆ្លើយតប ចំពោះបញ្ហាទាំងនោះ ដោយក្តីសង្ឃឹមឬ?

## អវត្តមាននៃក្តីសង្ឃឹម

ក្នុងអំឡុងពេលនៃវិបត្តិសេដ្ឋកិច្ចពិភពលោក កាលពីពេលថ្មីៗនេះ ខ្ញុំបានកត់សំគាល់ឃើញថា សហគមន៍ជាច្រើននៅទូទាំងពិភពលោក បានទទួលផលប៉ះពាល់ពីការវាយតម្លៃដ៏អន់ខ្សោយ អំពីវបត្តិសេដ្ឋកិច្ចពិភពលោក ដែលហៀបនឹងកើតឡើង។ ខ្ញុំក៏បានស្តាប់អ្នកវិភាគទាំងឡាយ ធ្វើការព្យាករណ៍ អំពីពេលដ៏ពិបាកនោះ។ ខ្ញុំមានអារម្មណ៍ពិបាក ពេលដែលបានដឹង អំពីបញ្ហាដែលហាក់ដូចជាគ្មាននរណាម្នាក់អាចដោះស្រាយបាន។



*យើងអះអាងថា យើងមាន ទំនាក់ទំនង ជាមួយព្រះនៃក្ដី សង្ឃឹម តែយើងច្រើនតែគិត អំពីជីវិត តាមទស្សនៈដែល អស់សង្ឃឹម។*

ប៉ុន្តែ ពេលដែលខ្ញុំបានក្លាយជាអ្នកដើរតាមព្រះគ្រីស្ទ ខ្ញុំក៏បានដឹងថា ការភ័យខ្លាច អារម្មណ៍នឿយណាយ និងការថប់បារម្ភ អំពីរឿងនយោបាយ គឺបណ្ដាលមកពីទស្សនៈដែលយើងមានចំពោះសង្គម ដែលនៅជុំវិញខ្លួនយើង។ ការសន្ទនា និងអារម្មណ៍របស់យើង ហាក់ដូចជាបានបញ្ជា ដោយការផ្សាយ និងរបាយការណ៍ផ្នែកហិរញ្ញវត្ថុ តាមបណ្ដាញអ៊ីនធើណិត។ ពេលនោះការបញ្ចេញមតិ និងអាកប្បកិរិយារបស់យើង បានបង្ហាញចេញនូវការភ័យខ្លាច និងកំហឹង ដូចអ្នកដែលមិនជឿព្រះ។ យើងហាក់ដូចជាគ្មានសង្ឃឹម នៅក្នុងខ្លួនសោះ។

អវត្តមាននៃក្ដីសង្ឃឹមនេះ គឺមិនគ្រាន់តែកើតមាន នៅក្នុងបញ្ហាសេដ្ឋកិច្ចប៉ុណ្ណោះទេ។ ក្ដីសង្ឃឹម និងក្ដីស្រមៃរបស់យើងអាចត្រូវបានស៊ីបំផ្លាញ យ៉ាងមានគ្រោះថ្នាក់ ដោយការបាត់បង់ និងថប់បារម្ភផ្ទាល់ខ្លួន។ លោកិយដែលសង្កេតមើលយើង អាចគិតថា ជំនឿរបស់យើងត្រូវបានលប់ពីលើ ដោយការសង្ស័យ អំពីពេលអនាគត។

តើការបាត់បង់ទំនុកចិត្តយ៉ាងដូចនោះ បានបង្ហាញថា យើងមានក្ដីជំនឿ និងក្ដីសង្ឃឹមបែបណា? តើជំនឿដែលយើងមានចំពោះព្រះ អាចត្រូវបានរុញច្រានចេញ ដោយ "ជំនឿបែបអ្នកមិនជឿព្រះឬ"?

បើយើងបានដាក់ជំនឿលើព្រះគ្រីស្ទហើយ ហេតុអ្វី ពេលខ្លះ យើងមានអារម្មណ៍ថា បញ្ហារបស់យើងហាក់ដូចជាធ្វើឲ្យយើងអស់សង្ឃឹម? យើងអះអាងថា យើងមានទំនាក់ទំនងជាមួយព្រះនៃក្ដីសង្ឃឹម តែយើងច្រើនតែគិតអំពីជីវិតខ្លួនឯង តាមទស្សនៈដែលគ្មានសង្ឃឹម។

## ទស្សនៈផ្ទុយគ្នា

លោកហ្វ្រេតឌ្រីជ នីតស៍ឈី(Friedrich Nietzsche) ធ្លាប់បាននិយាយថា "ក្ដីសង្ឃឹម គឺជាសេចក្ដីដែលអាក្រក់បំផុត ព្រោះវាបានធ្វើឲ្យមនុស្សទទួលរងទារុណកម្មកាន់តែយូរ"។

លោកអេរីក អេរីកសាន់(Erik Erikson) ដែលជាចិត្តវិទូអាមេរិក ដើមកំណើតដាណឺម៉ាក នៅសតវត្សទី២០ មានទស្សនៈខុសពីនេះ។ គាត់មានប្រសាសន៍ថា "ក្តីសង្ឃឹមគឺជាគុណធម៌ដើមដំបូងបំផុត និងមានតម្លៃបំផុត ដែលនៅជាប់នឹងការរស់រានមានជីវិត។ បើជីវិតត្រូវបន្ត នោះក្តីសង្ឃឹមត្រូវតែមាន សូម្បីតែនៅពេលដែលទំនុកចិត្តបានរងរបួស និងជំនឿទទួលរកការខូចខាតក៏ដោយ"។

ដូចនេះ តើទស្សនៈមួយណាត្រូវ? តើក្តីសង្ឃឹមជាសេចក្តីដែលអាក្រក់បំផុតដែលលើកកម្ពស់ទារុណកម្ម? ឬវាមានភាពចាំបាច់សម្រាប់ជីវិត ដូចខ្យល់ដង្ហើម?

***ក្នុងចំណោមស្នាដៃនិពន្ធជាច្រើន*** *របស់លោកហ្វ្រេឌ្រិជ នីតស៍ឈី(ឆ្នាំ១៨៤៤-១៩០០) ក្នុងផ្នែកទស្សនវិជ្ជា គាត់បានលើកយកទស្សនៈនៃការបញ្ជាក់អំពីជីវិត ដែលជឿលើភាពពិតនៃជីវិត នៅលើផែនដី ដោយមិនគិតអំពីជីវិតដែលមនុស្សនឹងមានបន្ទាប់ពីជីវិតនៅផែនដីនេះអស់ទៅ។ ផ្ទុយទៅវិញ ព្រះគម្ពីរបានបង្រៀនថា "របស់ដែលមើលឃើញ នោះស្ថិតស្ថេរមិនយូរប៉ុន្មានទេ តែឯរបស់ដែលមើលមិនឃើញ នោះនៅស្ថិតស្ថេរអស់កល្បជានិច្ចវិញ"(២កូរិនថូស ៤:១៨)។ លោកនីតស៍ឈីបានបោះបង់ជំនឿចោល ពេលដែលគាត់កំពុងសិក្សាទេវសាស្ត្រ នៅសកលវិទ្យាល័យបុន។*



*ទី២*

# អត្ថន័យនៃក្តីសង្ឃឹម

**នៅពេលព្រឹកថ្ងៃបុណ្យណូអែល** នៅឆ្នាំ១៩៦៤ ខ្ញុំចង់ស្វែងរកអំណោយតែមួយប៉ុណ្ណោះ នៅក្រោមដើមណូអែល។ អំណោយនោះ គឺជាហ្គីតាមួយគ្រឿង។ នៅឆ្នាំនោះ ក្រុមចម្រៀងប៊ីធលរបស់ចក្រភពអង់គ្លេស បានវាយលុកចូលទឹកដីសហរដ្ឋអាមេរិក ដូចខ្យល់ព្យុះ។ ពេលនោះខ្ញុំមានចិត្តចង់ក្លាយជាអ្នកលេងហ្គីតាដ៏ល្បីល្បាញបន្ទាប់ពីពួកគេ គឺមិនខុសពីយុវជនអាមេរិកជាច្រើនទៀតឡើយ។ នៅពេលព្រឹកថ្ងៃណូអែល ខ្ញុំក៏បានរត់ចុះតាមជណ្តើរបន្ទប់ទទួលភ្ញៀវ ដោយភ្នែកខំរកមើលរបស់ម្យ៉ាង ដែលមានរូបរាងដូចហ្គីតា។ តែរកមិនឃើញសោះ។ ផ្ទុយទៅវិញ ខ្ញុំបែរជារកឃើញវចនានុក្រមមួយក្បាល។

ពេលនោះ ខ្ញុំពិតជាពិបាកពិពណ៌នា អំពីការខកចិត្តក្នុងអារម្មណ៍របស់ខ្ញុំ។ ក្តីសង្ឃឹមថា នឹងបានក្លាយជាតន្ត្រីករដ៏អស្ចារ្យ ក៏ត្រូវបានរលាយ ដោយសារទំព័ររាប់រយ នៅក្នុងវនានុក្រម ដែលផ្ទុកទៅដោយនិយមន័យរបស់ពាក្យជាច្រើន។

ប៉ុន្តែ ឪពុកម្តាយខ្ញុំពិតជាមានប្រាជ្ញាណាស់។ ពេលដែលខ្ញុំពិចារណា អំពីការខកចិត្ត នៅថ្ងៃណូអែលនោះ ខ្ញុំក៏បានដឹងថា ហ្គីតាដែលខ្ញុំចង់បាននោះ មិនសូវមានប្រយោជន៍សម្រាប់ខ្ញុំ ដូចវចនានុក្រមនោះឡើយ ព្រោះវចនានុក្រមនោះ បានបង្រៀនខ្ញុំឲ្យចេះ និងយល់អត្ថន័យរបស់ពាក្យជាច្រើន។

សព្វថ្ងៃនេះ មិនមានពាក្យច្រើនទេ ដែលត្រូវការការពន្យល់អត្ថន័យឲ្យបានច្បាស់ ជាងពាក្យក្តីសង្ឃឹម ។ យើងចាំបាច់ត្រូវដឹងថា ក្តីសង្ឃឹមពិតប្រាកដជាអ្វី តែក៏ចាំបាច់ត្រូវដឹងថា តើមានក្តីសង្ឃឹមណាខ្លះ ដែលព្រះគ្រីស្ទមិនបានប្រទាន។

## អ្វីដែលព្រះយេស៊ូវមិនបានប្រទាន

មានពេលញឹកញាប់ពេកហើយ ដែលគេបានបន្ទាបតម្លៃរបស់ក្តីសង្ឃឹម ឲ្យមកនូវត្រឹមការគិតបែបប៉ងប្រាថ្នា ឬគ្រាន់តែជាការគិតវិជ្ជមាន។ យើងច្រើនតែឮគេប្រើពាក្យក្តីសង្ឃឹមយ៉ាងដូចនេះថា "ខ្ញុំសង្ឃឹមថា សេដ្ឋកិច្ចនឹងវិលត្រឡប់មកភាពដើមវិញ"។ "ខ្ញុំសង្ឃឹមថា ប្រទេសប្រេស៊ីលនឹងឈ្នះការប្រកួតពានរង្វាន់ពិភពលោក"។ "វេជ្ជបណ្ឌិតសង្ឃឹមថា ពួកគេអាចព្យាបាលជម្ងឺមហារីកជាសះស្បើយ"។

ពាក្យសម្តីនេះបង្ហាញអំពីក្តីប្រាថ្នាដែលមានក្នុងចិត្តនរណាម្នាក់។ ការសង្ឃឹមដូចនេះ គឺមិនមែនជារឿងខុសឆ្គងទេ តែវាមិនមែនជាក្តីសង្ឃឹមដែលព្រះគម្ពីរផ្តល់ឲ្យឡើយ។

ក្តីសង្ឃឹមដែលត្រូវបានបន្ទាបមកនូវត្រឹមកំរិតនៃការប៉ងប្រាថ្នា និងក្តីស្រមៃ គឺអាចមានលក្ខណៈដូចពពុះសាប៊ូ ដែលមើលទៅស្អាត ប៉ុន្តែ វានឹងរលាយ ពេលដែលយើងប៉ះវាតែបន្តិច។ គឺដូចដែលស្តេចសាឡូម៉ូនមានបន្ទូលថា "សេចក្តីសង្ឃឹមដែលចេះតែបន្ថយទៅ នោះនាំឲ្យអោ"(សុភាសិត ១៣:១២)។

ប្រហែលមកពីហេតុនេះហើយ បានជាលោកនីតស៍ឈី មានប្រត្តិកម្មខ្លាំងយ៉ាងនេះ ចំពោះទ្រឹស្តីអំពីក្តីសង្ឃឹម។ ក្តីស្រមៃបានធ្វើទារុណកម្មមកលើយើង ហើយបង្ហាញចេញនូវបំណងចិត្តរបស់យើង។ ប៉ុន្តែ បើវាមិនមានលទ្ធផលល្អអ្វីទេ យើងអាចមានការខកចិត្ត និងឈឺចាប់។

ក្តីសង្ឃឹមត្រូវតែមានមូលដ្ឋានពិតប្រាកដ។ វាត្រូវតែមានមូលដ្ឋានគ្រឹះរឹងមាំ។

ដូចនេះ តើក្តីសង្ឃឹមជាអ្វី?

> ***សុភាសិតរបស់ស្តេចសាឡូម៉ូន*** *ដែលមានជាបន្តបន្ទាប់ទៀត បានផ្តល់ឲ្យនូវក្តីសង្ឃឹមថា : កាលណាបានដូចប្រាថ្នា នោះប្រៀបដូចជាដើមឈើនៃជីវិតវិញ។ "ការដែលបានសំរេចតាមបំណងចិត្ត នោះមានរស់ផ្អែម ដល់ព្រលឹងហើយ" (សុភាសិត ១៣:១៩)។*

## ក្ដីសង្ឃឹមជាអ្វី?

សូម្បីតែនិយមន័យរបស់វចនានុក្រមក៏បានបង្ហាញថា ក្ដីសង្ឃឹមគួរតែមានមូលដ្ឋាន គឺមិនគ្រាន់តែជាការគិតបែបប៉ងប្រាថ្នា។ វចនានុក្រមមួយបានឲ្យនិយមន័យថា ក្ដីសង្ឃឹមគឺជា "ការប៉ងប្រាថ្នា ដែលមានការរំពឹងថា នឹងបាន ឬជាជំនឿថា នឹងបានសម្រេច"។

ក្ដីសង្ឃឹមអាចជាការរំពឹងចង់បាន និងរង់ចាំ ដែលផ្អែកទៅលើអ្វីដែលយើងជឿ។ បានសេចក្ដីថា សម្រាប់កូនរបស់ព្រះ ក្ដីសង្ឃឹមអាចមានលក្ខណៈរឹងមាំ ដូចអ្វីដែលយើងបានរៀនសូត្រអំពីសេចក្ដីល្អ និងសេចក្ដីស្មោះត្រង់របស់ព្រះជាម្ចាស់។ ក្ដីសង្ឃឹមក៏សំខាន់ ព្រោះវាបានបង្ហាញព្រះវត្តមាននៃព្រះវិញ្ញាណរបស់ព្រះ ក្នុងជីវិតយើង។

វាជាក្ដីសង្ឃឹម ដែលសាវ័កប៉ុលបានលើកមកនិយាយ ក្នុងសំបុត្រដែលគាត់បានសរសេរផ្ញើ ទៅកាន់ពួកជំនុំនៅទីក្រុងរ៉ូម។ សេចក្ដីបង្រៀនរបស់សាវ័កប៉ុល អំពីក្ដីសង្ឃឹម ក្នុងបទគម្ពីររ៉ូម ជំពូក១៥ ស្ថិតក្នុងចំណោមការបង្រៀនរបស់ព្រះគម្ពីរ អំពីក្ដីសង្ឃឹម ដែលងាយយល់បំផុត។ គឺដូចដែលគាត់បានបង្រៀនថា "ឥឡូវនេះ សូមព្រះនៃសេចក្ដីសង្ឃឹមប្រទានឲ្យអ្នករាល់គ្នាបានគ្រប់អស់ទាំងសេចក្ដីអំណរ និងសេចក្ដីសុខសាន្តដ៏ពោរពេញ ដោយសារសេចក្ដីជំនឿ ប្រយោជន៍ឲ្យបានសេចក្ដីសង្ឃឹមជាបរិបូរ ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ"(ខ.១៣)។

ការអធិស្ឋានដ៏អស្ចារ្យនេះ បានបង្ហាញនូវមូលហេតុសំខាន់ពីរយ៉ាង ដែលសេចក្ដីសង្ឃឹម គឺជាអទិភាព។ ទីមួយ ព្រះជាម្ចាស់ជាព្រះនៃសេចក្ដីសង្ឃឹម។ ក្ដីសង្ឃឹមរបស់យើង ដែលជាការរំពឹងចង់បានដោយអំណរ គឺមិនមែនគ្មានមូលដ្ឋានគ្រឹះនោះឡើយ។ គ្រឹះរបស់ក្ដីសង្ឃឹម មិនមែនជាទ្រឹស្ដី ឬទស្សនវិជ្ជានោះឡើយ តែជាអង្គបុគ្គល។ សាវ័កប៉ុលចង់ឲ្យយើងឱបក្រសោបយកក្ដីសង្ឃឹម ដែលបានចាក់ឫសក្នុងព្រះជាម្ចាស់ គឺមិនមែនជាអ្វីដែលយើងស្វែងរក ដោយប្រើកម្លាំងខ្លួនឯងនោះឡើយ។

***កណ្ឌគម្ពីររ៉ូម*** *ស្ថិតក្នុងចំណោមសំបុត្រដែលមានលក្ខណៈទេវសាស្ត្របំផុតរបស់សាវ័កប៉ុល តែក៏ត្រូវនឹងស្ថានភាពជាក់ស្ដែងផងដែរ។ សាវ័កប៉ុលបានសរសេរសំបុត្រនេះ សម្រាប់គ្រីស្ទបរិស័ទក្នុងទីក្រុងរ៉ូម ព្រោះគាត់មិនអាចទៅសួរសុខទុក្ខពួកគេដោយផ្ទាល់ ដោយសារមានការងារដែលបន្ទាន់ជាង នៅកន្លែងផ្សេង។*

ទីពីរ : សាវ័កប៉ុលចង់ឲ្យយើង "ពេញដោយក្តីសង្ឃឹម"។ ក្នុងនាមជាកូនព្រះ យើងបានទទួលព្រះវិញ្ញាណព្រះអង្គ និងក្តីសង្ឃឹមដ៏មានអំណាច ដែលចេញមកពីព្រះអង្គ។

អ្នកដើរតាមព្រះយេស៊ូវ គួរតែមានក្តីសង្ឃឹម ជាចរិកលក្ខណៈដ៏សំខាន់មួយ ព្រោះព្រះជាម្ចាស់ជាគ្រឹះនៃក្តីសង្ឃឹម និងព្រោះព្រះអង្គបានប្រទានយើងនូវព្រះវិញ្ញាណព្រះអង្គ។ ក្តីសង្ឃឹមពិតប្រាកដ ស្ថិតក្នុងចំណោមចរិកលក្ខណៈពិសេសបំផុត ដែលធ្វើឲ្យអ្នកជឿ មានលក្ខណៈដាច់ដោយឡែកពីអ្នកមិនស្គាល់ព្រះ។ ពេលដែលសាវ័កប៉ុលសរសេរសំបុត្រផ្ញើទៅពួកជំនុំនៅក្រុងអេភេសូរ គាត់បានពន្យល់ពួកគេ អំពីលក្ខណៈនៃជីវិតមុនពេលពួកគេទទួលសេចក្តីសង្គ្រោះ។ "នៅវេលានោះ អ្នករាល់គ្នានៅទីទៃពីព្រះគ្រីស្ទ ក៏ឃ្លាតចេញពីអំណាចជាតិអ៊ីស្រាអែលផង ជាមនុស្សដទៃខាងឯសេចក្តីសញ្ញា ដែលទ្រង់បានសន្យាទុក ក៏ឥតមានទីសង្ឃឹម ហើយគ្មានព្រះក្នុងលោកីយ៍នេះដែរ"(អេភេសូរ ២:១២)។

ឃ្លាចុងក្រោយ គឺសំខាន់ណាស់។ ពួកគេ "គ្មានសង្ឃឹម" ព្រោះពួកគេ "គ្មានព្រះក្នុងលោកិយនេះ"។ អ្នកជឿព្រះ គឺជាអ្នកមានក្តីសង្ឃឹម ដែលមានពេញដោយអំណរ។ នេះជាកត្តាដែលនាំឲ្យការរស់នៅយើង ខុសប្លែកពីអ្នកមិនជឿ។ បញ្ហាប្រឈមរបស់យើង គឺត្រូវរស់នៅ ដោយស្គាល់ក្តីសង្ឃឹមនោះ។

អ្នកប្រាជ្ញម្នាក់បាននិយាយថា សម្រាប់អ្នកដែលមិនស្គាល់ព្រះយេស៊ូវ ក្តីសង្ឃឹម មានថ្នាក់ពាក្យ ជាកិរិយាស័ព្ទ។ ប៉ុន្តែ សម្រាប់គ្រីស្ទបរិស័ទ ក្តីសង្ឃឹមមានថ្នាក់ពាក្យជានាម។ នេះជាភាពខុសគ្នាដ៏សំខាន់។ បានសេចក្តីថា ក្តីសង្ឃឹមមិនមែនជាអ្វី ដែលយើង ធ្វើ ដោយសង្កៀតធ្មេញ និងការរង់ចាំនោះទេ។

ក្តីសង្ឃឹម ដែលជាការរំពឹងចង់បាន ដោយអំណរ គឺជាអ្វីដែលយើងមាន ។ យើងមានសង្ឃឹម ព្រោះយើងស្គាល់ព្រះ ដែលជាប្រភព និងហេតុផល ដែលយើងត្រូវមានសង្ឃឹម។

ក្តីសង្ឃឹមពិតប្រាកដ មិនមែនជាការហួច ដើម្បីបន្លប់ការភ័យខ្លាច ពេលយើងដើរកាត់វាលកប់ខ្មោចម្នាក់ឯង ដោយសង្ឃឹមថា នឹងមិនមានរឿងអ្វីកើតឡើងនោះទេ។ ក្តីសង្ឃឹមពិតប្រាកដ មានភាពរស់រវើក និងមានអំណាច ព្រោះក្តីសង្ឃឹមនេះពិចារណា អំពីកាលៈទេសៈនៃជីវិត តាមការពិតជាក់ស្តែង ហើយបន្ទាប់មក សម្រាកដោយទំនុកចិត្ត នៅក្នុងព្រះបន្ទូលសន្យា និងចរិកលក្ខណៈរបស់ព្រះជាម្ចាស់។

## តើក្តីសង្ឃឹមពិតប្រាកដ មានលក្ខណៈដូចម្តេច?

ហេតុអ្វីបានជាមនុស្សមានការភ័ន្តច្រឡំច្រើនយ៉ាងនេះ អំពីលក្ខណៈពិតប្រាកដនៃក្តីសង្ឃឹម? មូលហេតុទីមួយ គឺដោយសារសេចក្តីសង្ឃឹមមានលក្ខណៈខុសៗគ្នា នៅស្ថានភាពខុសគ្នា គឺមិនខុសពីសេចក្តីជំនឿ និងសេចក្តីស្រឡាញ់នោះឡើយ។

ក្នុងបទគម្ពីរ ១កូរិនថូស ១៣:១៣ សាវ័កប៉ុលបានសរសេរថា "ឥឡូវនេះ នៅមានសេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ ទាំង៣មុខនេះ តែសេចក្តីដែលវិសេសជាងគេ គឺជាសេចក្តីស្រឡាញ់"។ សេចក្តីទាំងបីនេះ ជាសេចក្តីទាំងបីដ៏អស្ចារ្យ និងសំខាន់ ដែលនាំមកនូវក្តីអំណរក្នុងការរស់នៅ ប៉ុន្តែ សេចក្តីទាំងបីមានការសម្របខ្លួនយ៉ាងត្រឹមត្រូវ តាមស្ថានភាពដែលផ្លាស់ប្តូរ។

នៅពេលដែលមានភាពបរិបូរ សេចក្តីជំនឿអាចបង្ហាញចេញនូវជំនឿលើព្រះដោយការញញឹម ដោយការបន្ទាបខ្លួន ដោយការដឹងគុណ។ នៅពេលដែលមានការបាត់បង់ សេចក្តីជំនឿនឹងមានការសោកសង្រេង ប៉ុន្តែ មិនដូចមនុស្សដែលគ្មានសង្ឃឹមនោះទេ(១ថែស្សាឡូនិច ៤:១៣)។ ពេលណាសេចក្តីជំនឿធ្វើការ សេចក្តីជំនឿអាចបង្ហាញចេញមក តាមរយៈការប្រឹងប្រែងយ៉ាងខ្លាំង និងភាពបន្ទាន់។ នៅពេលសម្រាក សេចក្តីជំនឿអាចសម្រាក ក្នុងព្រះវត្តមាន នៃព្រះដែលមានបន្ទូលថា "ចូរបង្អង់សិន ឲ្យបានដឹងថា អញជាព្រះ"(ទំនុកដំកើង ៤៦:១០)។

សេចក្តីស្រឡាញ់ក៏មានការសម្របខ្លួនផងដែរ។ ដើម្បីស្វែងរកប្រយោជន៍សម្រាប់អ្នកដទៃ ជួនកាល សេចក្តីស្រឡាញ់ត្រូវតែមានភាពទន់ភ្លន់ និងអត់ធ្មត់។ នៅពេលខ្លះទៀត សេចក្តីស្រឡាញ់ត្រូវតែមានភាពរឹងមាំ ហើយថែមទាំងស្វិតស្វាញទៀតផង។ ក្តីសង្ឃឹមក៏អាចសម្របខ្លួន ឲ្យត្រូវតាមស្ថានភាពផ្សេងៗផងដែរ។ ព្រោះក្តីសង្ឃឹម ពឹងផ្អែកទៅលើសេចក្តីល្អ និងសេចក្តីស្មោះត្រង់របស់ព្រះ នោះក្តីសង្ឃឹមមានមុខខុសៗគ្នាជាច្រើន ដើម្បីឆ្លើយតបយ៉ាងពេញលេញ ចំពោះបទពិសោធន៍ខុសៗគ្នា ក្នុងជីវិត។

សាវ័កប៉ុលបានកត់សំគាល់ថា ក្តីសង្ឃឹមមានភាពក្លាហាន។ គឺដូចដែលគាត់បានពោលថា "ដែលមានសេចក្តីសង្ឃឹមជាខ្លាំងក្រៃដល់ម្ល៉េះ នោះយើងខ្ញុំកើតមានសេចក្តីក្លាហានណាស់"(២កូរិនថូស ៣:១២)។ គាត់ក៏បាននិយាយផងដែរថា ក្តីសង្ឃឹមមានភាពអត់ធ្មត់។ គឺដូចដែលគាត់បានពោលថា "យើងខ្ញុំអរព្រះគុណដល់ព្រះជានិច្ច ពីដំណើរអ្នករាល់គ្នា ... ដោយនឹកចាំជាដរាប ពីការដែលអ្នករាល់គ្នាធ្វើ

ដោយសេចក្តីជំនឿ និងពីការនឿយហត់ ដែលធ្វើដោយសេចក្តីស្រឡាញ់ ហើយដែលអ្នករាល់គ្នាមានសេចក្តីសង្ឃឹមយ៉ាងមាំមួន ដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា នៅចំពោះព្រះដ៏ជាព្រះវរបិតានៃយើងផង"(១ថែស្សាឡូនិច ១:២-៣)។

ក្តីសង្ឃឹមគឺជាការរំពឹងរង់ចាំ។ គឺដូចមានសេចក្តីចែងថា យើង"រង់ចាំសេចក្តីសង្ឃឹមដ៏មានពរ គឺឲ្យបានឃើញដំណើរលេចមកនៃសិរីល្អរបស់ព្រះដ៏ជាធំ និងព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃយើង ដែលទ្រង់បានថ្វាយព្រះអង្គទ្រង់ជំនួសយើងរាល់គ្នា ដើម្បីនឹងលោះយើងឲ្យរួចពីគ្រប់ទាំងសេចក្តីទទឹងច្បាប់ ហើយនិងសំអាតមនុស្ស១ពួក ទុកដាច់ជារាស្ត្ររបស់ផងទ្រង់ ដែលឧស្សាហ៍ធ្វើការល្អ"(ទីតុស ២:១៣-១៤)។

អ្នកនិពន្ធបទគម្ពីរហេព្រើរក៏បានបង្ហាញផងដែរថា ក្តីសង្ឃឹមគឺជាប្រភពនៃស្ថេរភាព បានជាគាត់សរសេរថា "យើងខ្ញុំមានសេចក្តីសង្ឃឹមនោះ ទុកដូចជាយុថ្កានៃព្រលឹងដ៏ជាប់លាប់មាំមួន ដែលចូលទៅខាងក្នុងនៃវាំងនន"(ហេព្រើរ ៦:១៩)។ សាវ័កយ៉ូហានក៏បានមានប្រសាសន៍ផងដែរថា ក្តីសង្ឃឹមពិតប្រាកដ នាំឲ្យមានការសម្អាតជាបរិសុទ្ធ។ "អស់អ្នកណាដែលមានសេចក្តីសង្ឃឹមយ៉ាងនេះដល់ទ្រង់ នោះក៏តែងជំរះសំអាតចិត្តខ្លួន ឲ្យដូចទ្រង់ដែលស្អាតដែរ"(១យ៉ូហាន ៣:៣)។

*វាំងនននោះគឺសំដៅទៅលើវាំងនន ដែលបែងចែកកន្លែងបរិសុទ្ធ ចេញពីកន្លែងបរិសុទ្ធបំផុត ក្នុងព្រះវិហារទីក្រុងយេរូសាឡិម។ មានតែសម្តេចសង្ឃទេ ដែលអាចចូលទៅក្នុងកន្លែងបរិសុទ្ធបំផុត នៅក្នុងការប្រារព្ធថ្ងៃឲ្យធួននឹងបាប ប្រចាំឆ្នាំមួយឆ្នាំម្តង។ ព្រះយេស៊ូវ(ជាសម្តេចសង្ឃតែមួយដែលគ្មានបាប) ជា "ក្តីសង្ឃឹម"របស់យើង ដែលអាចចូលទៅក្នុងវាំងនននោះ ដោយសេរី។*

ក្តីសង្ឃឹមពិតជាមានលក្ខណៈខុសៗគ្នា ដែលគួរឲ្យចាប់អារម្មណ៍ណាស់។ អ្នកដើរតាមព្រះគ្រីស្ទ អាចចូលទៅឈោងចាប់លោកិយ ដោយទំនុកចិត្ត ដោយសារពួកគេមានក្តីសង្ឃឹម។ ក្តីសង្ឃឹមពិតប្រាកដនឹងចម្រើនកម្លាំងយើង ឲ្យអាចប្រឈមមុខដាក់បញ្ហាផ្សេងៗ ព្រោះយើងអាចមើលទៅបញ្ហាប្រឈមទាំងនោះ ដោយផ្អែកទៅលើចរិកលក្ខណៈរបស់ព្រះជាម្ចាស់។

ដូចនេះ តើធ្វើដូចម្តេច ឲ្យយើងអាចមានក្តីសង្ឃឹមដ៏រឹងមាំ និងចេះសម្របខ្លួននោះ? ហើយតើក្តីសង្ឃឹមនោះមកពីណា?



*ទីបី*

# ប្រភពនៃក្តីសង្ឃឹម

**អ្នកនិពន្ធបទគម្ពីរទំនុកដំកើង** បានទទួលស្គាល់ថា ព្រះជាម្ចាស់ជាប្រភពនៃក្តីសង្ឃឹមរបស់យើង។ គាត់បានប្រកាស់ថា "ឥឡូវនេះ ឱព្រះអម្ចាស់អើយ តើទូលបង្គំនៅរង់ចាំអ្វីទៀត ដ្បិតទូលបង្គំសង្ឃឹមដល់ទ្រង់តែ១ប៉ុណ្ណោះ?"(ទំនុកដំកើង ៣៩:៧)។

ដើម្បីឲ្យយើងយល់ អំពីរបៀបដែលព្រះអម្ចាស់នាំក្តីសង្ឃឹម ចូលក្នុងជីវិតយើង ចូរយើងអានសំបុត្រដែលសាវ័កប៉ុលបានសរសេរផ្ញើទៅពួកជំនុំនៅទីក្រុងរ៉ូម ដែលបានចែងថា "ដ្បិតអស់ទាំងសេចក្តីដែលបានចែងទុកមកជាមុន នោះបានចែងសំរាប់នឹងបង្រៀនដល់យើងរាល់គ្នា ដើម្បីឲ្យយើងបានសេចក្តីសង្ឃឹម ដោយសេចក្តីអត់ធន់ និងសេចក្តីកំសាន្តចិត្ត ដោយសារគម្ពីរ"(រ៉ូម ១៥:៤)។ ប៉ុន្តែ តើសេចក្តីនោះបាននាំឲ្យយើងមានសង្ឃឹមដោយរបៀបណា?

## "**សេចក្តីអត់ធន់**"

ពេលដែលសាវ័កប៉ុលសរសេរ អំពីទំនាក់ទំនងរវាងសេចក្តីអត់ធន់ និងក្តីសង្ឃឹម គឺគាត់កំពុងតែនិយាយសំដៅទៅលើប្រភេទនៃការអត់ធ្មត់ ដែលកើតឡើង ពីការស្វែងរកប្រយោជន៍សម្រាប់អ្នកដទៃ(រ៉ូម ១៥:១-៣)។ ព្រះគ្រីស្ទបានស៊ូទ្រាំការឈឺចាប់ជំនួសយើងរាល់គ្នា ដើម្បីបង្ហាញឲ្យយើងស្គាល់ព្រះទ័យ និងសេចក្តីល្អរបស់ព្រះជាម្ចាស់(ខ.៣,៥-៧)។

ប្រវត្តិសាស្ត្របានបង្ហាញ អំពីតម្លៃនៃសេចក្តីអត់ធន់នេះ។ កាលពីចុងទសវត្សរ៍ឆ្នាំ ១៧០០ មានចលនាតូចមួយ ដែលមានការរីកធំឡើង បានព្យាយាមលប់បំបាត់ទាសភាព ក្នុងចក្រភពអង់គ្លេស ដូចនេះ ពួកគេត្រូវការសម្លេងគាំទ្រ នៅក្នុងរដ្ឋសភា

អង់គ្លេស។ អ្នកលប់បំបាត់ទាសភាពបានព្យាយាមបញ្ចុះបញ្ចូលលោកវីលៀម វីប៊ីហ្វ៊ស(William Wilberforce) ដែលជាសមាជិករដ្ឋសភា។ ជំនឿដែលគាត់មានចំពោះព្រះគ្រីស្ទ បានក្លាយជាមូលដ្ឋានគ្រឹះនៃការទាមទាសេរីភាព សម្រាប់មនុស្សទាំងអស់។

ប៉ុន្តែ ផ្លូវឆ្ពោះទៅរកការលប់បំបាតទាសភាព មិនមានភាពងាយស្រួលឡើយ។ ពួកអ្នកលប់បំបាត់ទាសភាពបានជួបនូវការលំបាកជាច្រើន។ លោកវីលប៊ីហ្វ៊សបានផ្តួចផ្តើមគំនិតម្តងហើយម្តងទៀត ដើម្បីបង្កើតច្បាប់លប់បំបាត់ការជួញដូរទាសករ ប៉ុន្តែ ច្បាប់នោះបានទទួលបរាជ័យយ៉ាងធ្ងន់ធ្ងរ។

យូរៗទៅ លោកវីលប៊ីហ្វ៊ស និងក្រុមរបស់គាត់ដែលកំពុងតែរីកធំ បានបន្តធ្វើឲ្យពួកប្រឆាំងចុះខ្សោយទៅៗ។ គាត់បានចំណាយទ្រព្យសម្បត្តិមួយផ្នែកធំ ហើយក៏បានប៉ះពាល់សុខភាពខ្លួនឯងផងដែរ។ ប៉ុន្តែ គាត់មានសេចក្តីអត់ធន់។
ទីបំផុត នៅថ្ងៃទី២៥ មីនា ឆ្នាំ១៨០៧ ស្តេចក៏បានចេញព្រះរាជក្រឹត្យគាំទ្រច្បាប់លប់បំបាត់ការជួញដូរទាសករ បន្ទាប់ពីលោកវីលៀម វីលប៊ីហ្វ៊ស និងក្រុមការងារគាត់បានស៊ូទ្រាំអស់រយៈពេល២០ឆ្នាំ។
លោកវីលប៊ីហ្វ៊ស និងមិត្តភក្តិរបស់គាត់ បានបង្ហាញថា សេចក្តីអត់ធន់អាចជួយយើងឲ្យឈានទៅដល់គោលដៅដ៏សក្តិសម។ សាវ័កប៉ុលបានយល់ឃើញថា គោលដៅនៃការស៊ូទ្រាំនោះ គឺជាសេចក្តីសង្ឃឹម។

ប៉ុន្តែ សាវ័កប៉ុលក៏បានឃើញទំនាក់ទំនងមួយទៀត រវាងក្តីសង្ឃឹម និងសេចក្តីអត់ធន់។ នៅក្នុងសំបុត្រដដែលនោះ គាត់បានសរសេរថា "មិនតែប៉ុណ្ណោះសោតយើងនៅតែអួតក្នុងកាលដែលមានទុក្ខលំបាកដែរ ដោយដឹងថា សេចក្តីទុក្ខលំបាកបង្កើតឲ្យមានសេចក្តីទ្រាំទ្រ សេចក្តីទ្រាំទ្របង្កើតឲ្យមានសេចក្តីសុាំថ្នឹក សេចក្តីសុាំថ្នឹកបង្កើតឲ្យមានសេចក្តីសង្ឃឹម ឯសេចក្តីសង្ឃឹមក៏មិនដែលនាំឲ្យយើងមានសេចក្តីខ្មាសឡើយ ពីព្រោះសេចក្តីស្រឡាញ់របស់ព្រះ បានផ្សាយមកសព្វក្នុងចិត្តយើងរាល់គ្នា ដោយសារព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះបានប្រទានមកយើងហើយ"(៥:៣-៥)។

យើងរកឃើញសេចក្តីពិតដ៏សំខាន់មួយ ក្នុងបទគម្ពីរខាងលើនេះ រួមនឹងបទគម្ពីររ៉ូម ១៥:៤។ យើងស៊ូទ្រាំ ដោយក្តីសង្ឃឹមថា នឹងបានសម្រេចគោលដៅដ៏សក្តិសមមួយ។ តែទន្ទឹមនឹងនោះ សេចក្តីអត់ធន់របស់យើងក៏បង្កើតឲ្យមានក្តីសង្ឃឹម។ ដូចនេះ ក្តីសង្ឃឹមជួយឲ្យយើងមានសេចក្តីអត់ធន់ ហើយសេចក្តីអត់ធន់ក៏នាំឲ្យមានក្តីសង្ឃឹម កាលណាយើងសម្រាកនៅក្នុងព្រះជាម្ចាស់។ យើងមិនអាចយល់បាន ឬ

មានក្តីសង្ឃឹមទាំងស្រុង ដោយគ្មានទុក្ខលំបាកនោះឡើយ ព្រោះទុក្ខលំបាកនាំឲ្យយើងត្រូវការការអត់ធ្មត់។ ក្នុងរដូវកាលនៃការតស៊ូ សេចក្តីអត់ធន់អនុញ្ញាតឲ្យយើងពិសោធន៍នឹងក្តីស្រឡាញ់របស់ព្រះ តាមរបៀបថ្មី។ ហើយក្តីសង្ឃឹមដែលកើតចេញពីការលំបាក នឹងកាន់តែមានភាពជ្រាលជ្រៅ និងប្រសើរលើសអ្វីដែលយើងអាចរកបាន តាមរយៈភាពងាយស្រួល ឬផាសុខភាព។



*យើងមិនអាចយល់បាន ឬមានក្តីសង្ឃឹមទាំងស្រុង ដោយគ្មានទុក្ខលំបាកនោះឡើយ ព្រោះទុក្ខលំបាកនាំឲ្យយើងត្រូវការការអត់ធ្មត់។*

នៅក្នុងសេចក្តីអត់ធន់ យើងអាចពិសោធន៍នឹងៈ **ក្តីសង្ឃឹម និងព្រះគុណព្រះ។** ក្នុងការអ្វីដែលយើងមិនអាចធ្វើបាន យើងត្រូវដឹងថា ព្រះគុណរបស់ព្រះលើសពីគ្រប់គ្រាន់សម្រាប់យើង។ ក្នុងពេលដែលយើងខ្វះខាត ព្រះអង្គឆ្លើយតប ដោយព្រះគុណហៀរហូរ។ សាវ័កប៉ុលបានដឹងថា ព្រះគុណព្រះធំប្រសើរលើសរដូវកាលទាំងអស់នៃទុក្ខវេទនា។ គាត់បានទូលសូមព្រះជាម្ចាស់បីដង ឲ្យរំដោះគាត់ ឲ្យរួចពីទុក្ខលំបាកមួយ។

គាត់បានកត់ទុក អំពីការឆ្លើយតបរបស់ព្រះជាម្ចាស់ ក្នុងបទគម្ពីរ ២កូរិនថូស ១២:៩ ។ គឺដូចដែលព្រះអង្គបានឆ្លើយតបថា : "គុណរបស់អញល្មមដល់ឯងហើយ ដ្បិតកំឡាំងអញបានពេញខ្នាត ដោយសេចក្តីកំសោយ"។ សាវ័កប៉ុលក៏បានឆ្លើយតបថា "ដូច្នេះ ខ្ញុំនឹងស៊ូអួតពីសេចក្តីកំសោយរបស់ខ្ញុំ ដោយអំណរជាខ្លាំង ដើម្បីឲ្យព្រះចេស្តានៃព្រះគ្រីស្ទបានសណ្ឋិតនៅនឹងខ្ញុំ"។

**ក្តីសង្ឃឹម និងការការពារមកពីព្រះ។** ភាពមិនច្បាស់លាស់នៃជីវិត អាចធ្វើឲ្យចិត្តយើងមានការភ័យខ្លាច។ ប៉ុន្តែ ពេលណាយើងស៊ូទ្រាំ ដោយជំនឿ យើងនឹងរកឃើញថា ព្រះជាម្ចាស់ការពារយើង សូម្បីតែនៅពេលដែលខ្មៅងងឹតបំផុត។ សុវត្ថិភាពរបស់យើង ក្នុងព្រះគ្រីស្ទ នាំឲ្យយើងមានសង្ឃឹម តាមរយៈព្រះចេស្តាព្រះអង្គសម្រាប់អ្នកដើរតាមព្រះគ្រីស្ទ ដែល "ព្រះចេស្តានៃព្រះកំពុងតែថែរក្សា ដោយសារសេចក្តីជំនឿ សំរាប់ឲ្យបានសេចក្តីសង្គ្រោះ ដែលប្រុងប្រៀបនឹងសំដែងមកនៅជាន់ក្រោយបង្អស់នោះ" (១ពេត្រុស ១:៥)។

អំណាចចេស្តារបស់ព្រះ ជាប្រភពដ៏អស្ចារ្យនៃក្តីសង្ឃឹម បានជាអ្នកនិពន្ធទំនុកដំកើងបានថ្វាយបង្គំព្រះ ដោយបន្លឺសម្លេងថា :

តែទូលបង្គំនឹងច្រៀងពីព្រះចេស្តានៃទ្រង់
អើ ចាប់តាំងពីព្រលឹមស្រាង
នោះទូលបង្គំនឹងបន្លឺសំឡេង
ច្រៀងពីសេចក្តីសប្បុរសរបស់ទ្រង់
ដ្បិតទ្រង់ជាប៉មយ៉ាងខ្ពស់នៃទូលបង្គំ
ហើយជាទីជ្រក នៅថ្ងៃដែលទូលបង្គំមានសេចក្តីវេទនា( ទំនុកដំកើង ៥៩:១៦ )។

យើងមិនចាំបាច់ត្រូវរស់នៅ ដោយចិត្តភ័យខ្លាច ឬអស់សង្ឃឹមនោះឡើយ។ តែយើងអាចរស់នៅ ដោយការរំពឹងចង់បាន ដោយទំនុកចិត្ត។

**ក្តីសង្ឃឹម និងការផ្គត់ផ្គង់របស់ព្រះ។** យោងតាមអ្នកនិពន្ធបទគម្ពីរហេព្រើរ ដោយសារព្រះយេស៊ូវជ្រាបអំពីភាពកម្សោយ និងការល្បួងដែលយើងជួប នោះយើងអាច "មកដល់បល្ល័ង្កនៃព្រះគុណ ដោយក្លាហាន ដើម្បីនឹងទទួលសេចក្តីមេត្តា ហើយរកបានព្រះគុណសំរាប់នឹងជួយដល់ពេលត្រូវការ"( ៤:១៦ )។

ព្រះគុណ ការការពារ និងការផ្គត់ផ្គង់របស់ព្រះ ជាប្រភពនៃក្តីសង្ឃឹម ដែលយើងត្រូវពិសោធន៍ នឹងសេចក្តីទាំងបីនេះ ក្នុងពេលដែលមានទុក្ខលំបាក ទើបយើងអាចយល់អំពីសេចក្តីទាំងបីនេះទាំងស្រុង។ តែកាលណាយើងក្រឡេកមករកពេល ដែលយើងបានឆ្លងកាត់ហើយ យើងអាចនិយាយតាមសាវ័កប៉ុលថា "យើងខ្ញុំត្រូវគេសង្កត់សង្កិនគ្រប់ជំពូក តែមិនទ័លផ្លូវឡើយ មានសេចក្តីវិលវល់ តែមិនទ័លគំនិតទេ មានគេធ្វើទុក្ខ តែមិនមែនត្រូវចោលនៅម្នាក់ឯងទេ ត្រូវគេវាយដួលស្តូក តែមិនស្លាប់ទេ"(២កូរិនថូស ៤:៨-៩ )។



*អំណាចចេស្តារបស់ព្រះ គឺជាប្រភពនៃក្តីសង្ឃឹម*

ការពិតដែលសាវ័កប៉ុលបានលើកមកនិយាយនេះ គឺជាការរំឭកដ៏ស្មោះត្រង់ថា អ្នកដើរតាមព្រះគ្រីស្ទ មិនអាចជៀសផុត ពីការឈឺចិត្ត ភាពរឹករវ បញ្ហាប្រឈម និងការតស៊ូនោះឡើយ។ យើងនឹងជួប "គ្រោះថ្នាក់ ទុក្ខលំបាក និងអន្ទាក់ជាច្រើន" ប៉ុន្តែ មិនដូចអ្នកដែលគ្មានព្រះ ឬគ្មានសង្ឃឹមនោះឡើយ។ ដោយសារវត្ថុបំណងនៃជំនឿរបស់យើង នោះយើងដែលជាអ្នកដើរតាមព្រះគ្រីស្ទ ជាមនុស្សដែលមានក្តីសង្ឃឹមពិតប្រាកដ។

## ការរកឃើញក្ដីសង្ឃឹម នៅក្នុងរឿងក្នុងព្រះគម្ពីរ

ព្រះជាម្ចាស់បានធ្វើការក្នុងជីវិតបុរស និងស្ត្រីជាច្រើន ដែលមានលក្ខណៈដូចយើងដែរ ដើម្បីបង្ហាញថា ព្រះអង្គមានសមត្ថភាពធ្វើការជំនួសយើង។ អ្នកទាំងនោះបានរៀនសូត្របានថា ពួកគេអាចទុកចិត្តព្រះជាម្ចាស់ ក្នុងពេលដែលមានការពិបាកបំផុត។ សាវ័កយ៉ាកុបដែលជាអ្នកនិពន្ធកណ្ឌគម្ពីរសញ្ញាថ្មី បានលើកទឹកចិត្តយើង ឲ្យរៀនសូត្រពីបទពិសោធន៍របស់ពួកគេ។ គឺដូចដែលគាត់បានសរសេរថា "បងប្អូនអើយ ចូរយកពួកហោរា ដែលបានទាយដោយនូវព្រះនាមព្រះអម្ចាស់ ទុកជាគំរូពីសេចក្ដីទុក្ខលំបាក និងពីសេចក្ដីអត់ធ្មត់ចុះ"(យ៉ាកុប ៥:១០)។

កាលស្ដេចដាវីឌនៅក្មេង ទ្រង់បានចេញប្រយុទ្ធក្នុងសមរភូមិ ពេលដែលកូលីយ៉ាតចង់តតាំងនឹងកងទ័ព និងព្រះរបស់សាសន៍អ៊ីស្រាអែល។ បទគម្ពីរ ១សាំយ៉ូអែល ជំពូក ១៧ បានប្រាប់យើងថា ស្ដេចដាវីឌបានស្ម័គ្រព្រះទ័យចេញទៅប្រឈមមុខដាក់អ្នកប្រយុទ្ធជើងឯករបស់ពួកភីលីស្ទីន ព្រោះកន្លងមក ព្រះជាម្ចាស់បានធ្វើឲ្យទ្រង់អាចការពារហ្វូងចៀមរបស់ឪពុកគាត់ ឲ្យរួចពីការវាយប្រហាររបស់សត្វតោ និងសត្វខ្លាឃ្មុំ(ខ.៣៤-៣៧)។ ដោយសារទ្រង់ធ្លាប់បានពិសោធន៍នឹងការការពារដ៏ស្មោះត្រង់របស់ព្រះជាម្ចាស់ ក្នុងការប្រឈមមុខដាក់គ្រោះថ្នាក់ កាលពីលើកមុន នោះទ្រង់ក៏មានការរំពឹង ដោយទំនុកចិត្តថា ទ្រង់នឹងមានជ័យជម្នះទៀត។

*បទទំនុកដំកើងជាច្រើនរបស់ស្ដេចដាវីឌ បាននិយាយអំពីសេចក្ដីសង្ឃឹម។ ឧទាហរណ៍ ក្នុងបទគម្ពីរទំនុកដំកើង ជំពូក៣៩ ស្ដេចដាវីឌបានមានបន្ទូល អំពីភាពនឿយណាយរបស់ទ្រង់ ចំពោះមនុស្សអាក្រក់ ដែលប្រឆាំងនឹងទ្រង់។ ទ្រង់បានរក្សាភាពស្ងៀមស្ងាត់ ក្នុងពេលដែលគេចោទប្រកាន់ទ្រង់។ ចំណុចសំខាន់*

ក្នុងបទគម្ពីរដានីយ៉ែល ជំពូក៣ ជនជាតិយូដាបីនាក់ ដែលជាឈ្លើយសឹក នៅចក្រភពបាប៊ីឡូន ត្រូវបានគេបញ្ជា ឲ្យក្រាប នៅចំពោះរូបព្រះដ៏ធំមួយ ដើម្បីបង្អាប់ព្រះនាមនៃព្រះដ៏ពិត។ ពេលនោះ ពួកគេនឹកចាំ អំពីការដែលព្រះទ្រង់បានរំដោះពួកគេ ពេលដែលជំនឿរបស់ពួកគេជួបការប្រឆាំង(ដានីយ៉ែល ជំពូក ១) និងពេលដែលជីវិតពួកគេបានទទួលរងការគំរាមកំហែង(ដានីយ៉ែល ជំពូក ២) ដូចនេះ ពួកគេក៏បានឈរយ៉ាងមុំមួន។ បទពិសោធន៍ដែលពួកគេមានជាមួយព្រះអង្គ កាលពី

មុន បានរៀបចំខ្លួនពួកគេ ឲ្យទុកចិត្តព្រះអង្គ ក្នុងពេលដែលមានការពិបាកនេះផង ដែរ។

យើងបានស្តាប់ និងអានរឿងទាំងអស់នេះ ញឹកញាប់ណាស់ បានរឿងទាំងនេះ មិនសូវមានឥទ្ធិពលមកលើយើង។ ប៉ុន្តែ អ្នកទាំងអស់នោះមិនមែនជាវីរបុរសដ៏អស្ចារ្យ ដែលមានសមត្ថភាពពិសេសនោះឡើយ។ ពួកគេគ្រាន់តែជាមនុស្សធម្មតា ដែលបានជួបបញ្ហាប្រឈមក្នុងជីវិត។

ពួកគេបានប្រឈមមុខដាក់បញ្ហាទាំងនោះ ដោយក្តីសង្ឃឹម ព្រោះបទពិសោធន៍ ដែលពួកគេមានជាមួយព្រះ កាលពីមុន បានប្រាប់ពួកគេថា ទ្រង់សក្តិសមនឹងឲ្យពួកគេជឿទុកចិត្ត។ ការភ័យខ្លាច និងការថប់បារម្ភ បានប្រែក្លាយជាការទុកចិត្ត និងការរំពឹងចង់បាន ព្រោះព្រះជាម្ចាស់បានបង្ហាញឲ្យពួកគេដឹងថា ព្រះអង្គតែងតែស្មោះត្រង់ជានិច្ច។

ព្រះគម្ពីរបានផ្តល់ឲ្យយើងនូវក្តីសង្ឃឹម ព្រោះព្រះដែលមានចែងក្នុងព្រះគម្ពីរប៊ីប មិនគ្រាន់តែជាព្រះរបស់ពួកគេប៉ុណ្ណោះទេ តែព្រះអង្គជាព្រះរបស់យើងផងដែរ។ ហើយព្រះអង្គមិនដែលប្រែប្រួលឡើយ។ ព្រះអង្គនៅតែអាច "នឹងធ្វើហួសសន្ធឹក លើសជាងអស់ទាំងសេចក្តីដែលយើងសូម ឬគិតក្តី តាមព្រះចេស្តា ដែលបណ្តាលក្នុងយើងរាល់គ្នា"(អេភេសូរ ៣:២០)។



## ទី៤

# ភ្លើសង្ឃឹម សម្រាប់លោកិយ ដែលគ្មានសង្ឃឹម

**អ្នកដើរតាមព្រះគ្រីស្ទគួរតែមានលក្ខណៈ**ខុសពីអ្នកដែលមិនស្គាល់ព្រះអង្គ នៅត្រង់ចំណុច ដែលថា យើងគួរតែរស់នៅជាមនុស្សដែលមានសង្ឃឹម។ នេះជាការពិត ដែលស្ថិតនៅក្នុងចំណុចស្នូល នៃបេសកកម្មនៃការផ្សាយអំពីព្រះគ្រីស្ទដល់អ្នកដទៃ។ យើងមិនផ្តល់ឲ្យគេនូវសាសនា ទស្សនៈ ឬទស្សនវិជ្ជាថ្មីមួយនោះទ្បើយ។ តែយើងផ្តល់ឲ្យពួកគេនូវសេចក្តីសង្ឃឹម ដែលលោកិយកំពុងតែស្រេកឃ្លាន។

យើងច្រើនតែភ្លេចរឿងនេះ។ បេសកកម្មរបស់យើង គឺមិនគ្រាន់តែផ្សាយអំពីការអត់ទោសបាបរបស់ព្រះ និងនាំគេឲ្យមានទំនាក់ទំនងជាមួយព្រះអង្គប៉ុណ្ណោះទ្បើយ តែក៏ត្រូវនាំគេឲ្យទទួលសេចក្តីសង្ឃឹម ដែលបានមកពីទំនាក់ទំនងជាមួយព្រះអង្គ។

សាវ៉កពេត្រុសបានបង្រៀនយើងថា "ចូរឲ្យតាំងព្រះគ្រីស្ទទ្បើង ជាបរិសុទ្ធ នៅក្នុងចិត្តអ្នករាល់គ្នា ទុកជាព្រះអម្ចាស់ចុះ ហើយឲ្យប្រុងប្រៀបជានិច្ច ដោយសុភាព ហើយកោតខ្លាច ដើម្បីនឹងតបឆ្លើយដល់អ្នកណាដែលសួរពីហេតុនៃសេចក្តីសង្ឃឹមរបស់អ្នករាល់គ្នា"(១ពេត្រុស ៣:១៥)។ បទគម្ពីរនេះ ប្រហែលជាបទគម្ពីរដែលមានការបកស្រាយល្អបំផុត អំពីរឿងនេះ។

*និយាយឲ្យងាយស្តាប់ ការញែកជាបរិសុទ្ធ គឺជា "ការធ្វើឲ្យយើងបរិសុទ្ធ" "ឬថ្វាយដាច់"។ គឺជាការញែកចេញ សម្រាប់ការប្រើប្រាស់ខាងវិញ្ញាណ ឬខាងជំនឿ។*



*យើងផ្តល់ឲ្យពួកគេនូវ សេចក្តីសង្ឃឹម ដែល លោកិយកំពុងតែស្រេកឃ្លាន។*

ខ្ញុំធ្លាប់ឮគេបង្រៀនខគម្ពីរនេះ រាប់សិបដងមកហើយ។ ខ្ញុំក៏បានអានសេចក្តីពន្យល់ជាច្រើន ដែលបានបកស្រាយការបង្រៀនរបស់សាវ័កពេត្រុសក្នុងបទគម្ពីរនេះ។ ខ្ញុំថែមទាំងបាននិយាយ អំពីបរិបទនេះ ដោយខ្លួនឯងផ្ទាល់ផងដែរ។ ភាគច្រើន យើងប្រើបទគម្ពីរ ១ពេត្រុស ៣:១៥ ដោយការបកស្រាយមិនគ្រប់ជ្រុងជ្រោយ។

តាមធម្មតា គេបានយកបទគម្ពីរនេះ មកបង្រៀនថា "ក្នុងនាមជាអ្នកជឿ យើងចាំបាច់ត្រូវរៀនផ្សព្វផ្សាយជំនឿរបស់យើង។ យើងចាំបាច់ត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាល និងសិក្ខាសាលា។ យើងត្រូវតែរៀនខគម្ពីរយុទ្ធសាស្ត្រមួយចំនួន ដែលអាចបកស្រាយព្រះរាជសារអំពីឈើឆ្កាងបានច្បាស់លាស់។ យើងត្រូវតែធ្វើការទាំងអស់នេះ ព្រោះសាវ័កពេត្រុសបានបង្គាប់យើង ឲ្យត្រៀមខ្លួនដើម្បីឆ្លើយតប ចំពោះសំណួររបស់គេជានិច្ច"។

ការនិយាយដូចនេះ គឺមិនខុសទេ។ ព្រះគ្រីស្ទបានត្រាស់ហៅយើង ឲ្យនាំសារនៃដំណឹងល្អ ទៅកាន់ចុងបំផុតនៃផែនដី។ យើងត្រូវតែផ្សាយព្រះរាជសារនៃសេចក្តីស្រឡាញ់ និងការអត់ទោសបាបរបស់ព្រះអង្គ។ ប៉ុន្តែ ការបកស្រាយ អំពីបទគម្ពីរ ១ពេត្រុស ៣:១៥ ខាងលើនេះ មិនគ្រប់ជ្រុងជ្រោយឡើយ។

តាមពិត លោកពេត្រុសកំពុងតែបង្រៀនយើងថា មានគន្លឹះមួយ ដែលនាំឲ្យយើងមានឱកាសផ្សាយដំណឹងល្អ។ តែគន្លឹះនោះជាអ្វី? គឺជាសេចក្តីសង្ឃឹមក្នុងជីវិតយើង ដែលនាំឲ្យយើងមានឱកាសផ្សាយដំណឹងល្អ។

សរុបមក សេចក្តីសង្ឃឹម ដែលគេឃើញមានក្នុងជីវិតយើង នាំឲ្យការផ្សាយដំណឹងល្អមានប្រសិទ្ធភាព ហើយសេចក្តីសង្ឃឹមនោះ គឺមិនគ្រាន់តែជាការចេះព្រះគម្ពីរប៉ុណ្ណោះឡើយ។

ក្នុងបទគម្ពីរនេះ លោកពេត្រុសកំពុងតែប្រាប់យើងថា:

- យើងត្រូវរស់នៅ ជាមនុស្សនៃក្តីសង្ឃឹម
- ក្តីសង្ឃឹម គឺជាសញ្ញាសម្គាល់ ដែលធ្វើឲ្យយើងខុសប្លែកពីអ្នកមិនជឿ
- មនុស្សដែលកំពុងរស់នៅ ដោយគ្មានសង្ឃឹម និងស៊ូទ្រាំនឹងលោកិយដែលគ្មានសង្ឃឹម នឹងបានឃើញភាពខុសប្លែក ក្នុងជីវិតយើង ដែលបានកើតឡើងពីក្តីសង្ឃឹម

- ពួកគេនឹងសួរយើងថា ក្តីសង្ឃឹមយើងបានមកពីណា
- បន្ទាប់មក យើងអាចត្រៀមខ្លួន ដើម្បីឆ្លើយប្រាប់គេ

ពួកគេនឹងមើលឃើញក្តីសង្ឃឹម ក្នុងយើង ហើយចង់បានក្តីសង្ឃឹមនោះផងដែរ។ ពួកគេនឹងសួរយើងថា យើងបានក្តីសង្ឃឹមនោះមកពីណា។ ហើយយើងត្រូវត្រៀមខ្លួនឆ្លើយប្រាប់គេ។ ដរាបណាជីវិតយើង មិនមានក្តីសង្ឃឹមពិតប្រាកដ ដ៏រស់ និងពេញដោយទំនុកចិត្តទេ នោះគេនឹងមិនឃើញយើងខុសប្លែកពីគេឡើយ ហើយក៏នឹងគ្មាននរណាសួរយើងដែរ។



*ក្តីសង្ឃឹម ធ្វើឲ្យយើង មានលក្ខណៈខុសពី អ្នកមិនជឿ។*

យើងអាចរៀនខគម្ពីរ និងវិធីសាស្ត្រទាំងអស់។ យើងអាចរៀនយុទ្ធសាស្ត្រ និងទ្រឹស្តីផ្សាយដំណឹងល្អ។ យើងអាចមានចិត្តអាណឹតអ្នកដែលកំពុងស្វែងរកសេចក្តីពិត។ ប៉ុន្តែ បើយើងគ្មានក្តីសង្ឃឹមជាកស្តុតាង ក្នុងលោកិយដែលគ្មានសង្ឃឹមទេ នោះយើងមិនអាចបង្ហាញមនុស្សដែលគ្មានសង្ឃឹម ឲ្យឃើញអ្វីដែលខុសប្លែកពីភាពគ្មានសង្ឃឹមដែលពួកគេបានស្គាល់ហើយនោះឡើយ។

ក្នុងព្រះគ្រីស្ទ យើងមានក្តីសង្ឃឹមពិតប្រាកដ គឺមិនមែនខ្វះការយល់ដឹង អំពីភាពពិតរបស់ជីវិតនោះឡើយ។ ពីដំបូង មនុស្សជុំវិញខ្លួនយើង ប្រហែលជាឆ្ងល់ថា យើងហាក់ដូចជាចម្លែក ព្រោះក្តីសង្ឃឹមដែលគេមិនយល់នោះ គឺជាសញ្ញាសំគាល់ នូវភាពខុសប្លែកក្នុងជីវិតយើង។ ប៉ុន្តែ ក្នុងលោកិយដែលស្រេកឃ្លានក្តីសង្ឃឹម បុរស និងស្ត្រីទាំងឡាយ នឹងមានចិត្តចង់បានក្តីសង្ឃឹមដ៏ពិត ហើយក្តីសង្ឃឹមដ៏ពិតនោះ នឹងនាំពួកគេឲ្យងាកទៅរកព្រះគ្រីស្ទ ដែលមានតែការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គប៉ុណ្ណោះ ដែលបានធ្វើឲ្យក្តីសង្ឃឹមនោះ អាចកើតមានបាន។ ក្តីសង្ឃឹមនឹងការមានព្រះជន្មរស់ឡើងវិញ គឺមានការជាប់ទាក់ទងគ្នា ដែលមិនអាចកាត់ផ្តាច់បាន។



**ទី៥**

# មូលដ្ឋានគ្រឹះនៃក្តីសង្ឃឹម

**អំណាចនៃការមានព្រះជន្មឡើងវិញរបស់ព្រះគ្រីស្ទ។** សំបុត្រទី១ របស់លោកពេត្រុស ក៏បាននិយាយ អំពីសារៈសំខាន់នៃការមានព្រះជន្មរស់ឡើងវិញ របស់ព្រះគ្រីស្ទ។ គឺដូចមានសេចក្តីចែងថា "សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានបង្កើតយើងឡើងជាថ្មី តាមសេចក្តីមេត្តាករុណាដ៏ធំរបស់ទ្រង់ ដើម្បីឲ្យយើងរាល់គ្នាបានសេចក្តីសង្ឃឹមដ៏រស់ ដោយសារព្រះយេស៊ូវគ្រីស្ទ ទ្រង់រស់ពីស្លាប់ឡើងវិញ"(១ពេត្រុស ១:៣)។ ក្នុងបទគម្ពីរនេះ យើងឃើញថា ក្តីសង្ឃឹមរបស់យើង មានប្រភពមកពីសេចក្តីពិតដែលថា ព្រះយេស៊ូវគ្រីស្ទ បានឈ្នះអំពើបាប ជំនួសយើងហើយ។

ព្រះគម្ពីរបានចែងអំពីខ្មាំងសត្រូវធំបំផុតរបស់យើង យ៉ាងដូចនេះថា :

- សេចក្តីស្លាប់គឺជាលទ្ធផល នៃអំពើបាបរបស់យើង។ "ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់"(រ៉ូម ៦:២៣)។
- ការឈឺចាប់ក្នុងជីវិតយើង គឺប្រៀបដូចជា "ជ្រលងនៃម្លប់នៃសេចក្តីស្លាប់"(ទំនុកដំកើង ២៣:៤)។
- ការឈឺចាប់នៃសេចក្តីស្លាប់ គឺជាប្រភពដំបូងនៃការភ័យខ្លាចរបស់យើង។ "ចិត្តទូលបង្គំអន្ទះសានៅក្នុងខ្លួនហើយសេចក្តីស្ញែងខ្លាចចំពោះសេចក្តីស្លាប់បានគ្របសង្កត់លើទូលបង្គំ"(ទំនុកដំកើង ៥៥:៤)។
- សេចក្តីស្លាប់គឺជាការតម្រូវដែលមិនអាចជៀសវៀងបាន។ "ហើយដោយព្រោះបានតម្រូវឲ្យមនុស្សទាំងអស់ស្លាប់១ដង រួចសឹមជាប់សេចក្តីជំនុំជំរះ"(ហេព្រើរ ៩:២៧)។

សេចក្តីស្លាប់ គឺពិតជាសត្រូវដ៏ធំរបស់យើង ដែលយើងមិនអាចឈ្នះ ដោយខ្លួនឯងបានឡើយ។ ហេតុនេះហើយ ព្រះគ្រីស្ទបានយាងមកដោះស្រាយបញ្ហានៃសេចក្តីស្លាប់ ជំនួសយើង និងដើម្បីប្រទានក្តីសង្ឃឹម ដល់យើង។

ក្តីសង្ឃឹមថា នឹងឈ្នះសេចក្តីស្លាប់ ដែលព្រះគ្រីស្ទបានប្រទាន គឺមានភាពអស្ចារ្យណាស់ បានជាកណ្ឌគម្ពីរម៉ាថាយ បានរំឮកអ្នកអានរបស់ខ្លួន ឲ្យនឹកចាំ អំពីបទទំនាយរបស់ហោរាអេសាយ ដែលបានចែងថា :

"ឯបណ្តាជន ដែលអង្គុយក្នុងសេចក្តីងងឹត គេបានឃើញពន្លឺយ៉ាងធំ មានពន្លឺរះឡើង បំភ្លឺដល់ពួកអ្នកដែលអង្គុយក្នុងកំលុង ហើយនឹងម្លប់នៃសេចក្តីស្លាប់"(ម៉ាថាយ ៤:១៦)។

ព្រះគ្រីស្ទបាននាំយើងចេញពីសេចក្តីងងឹត ចូលពន្លឺ ពីសេចក្តីស្លាប់ចូលទៅក្នុងជីវិត។ ព្រះអង្គបានឈ្នះសេចក្តីស្លាប់ ដកការភ័យខ្លាចសេចក្តីស្លាប់ចេញ ហើយជំនួសមកវិញ ដោយក្តីសង្ឃឹម។

សូមយើងពិចារណា អំពីឥទ្ធិពលនៃការអ្វីដែលការសុគត និងការមានព្រះជន្មឡើងវិញរបស់ព្រះគ្រីស្ទសម្រេចបាន។ សាវ័កប៉ុលបានបកស្រាយអំពីបញ្ហានេះ ក្នុងបទគម្ពីរ ១កូរិនថូស ជំពូក១៥ ដោយពន្យល់អំពីជម្រៅ និងភាពអាចយល់បាន នៃជ័យជម្នះ ដែលការសុគតរបស់ព្រះគ្រីស្ទសម្រេចបាន។ គឺដូចដែលគាត់បានសរសេរថា :

"ឯខ្មាំងសត្រូវក្រោយបង្អស់ ដែលត្រូវបំផ្លាញ គឺជាសេចក្តីស្លាប់...កាលណារូបកាយពុករលួយនេះ បានប្រដាប់ដោយសេចក្តីមិនពុករលួយ ហើយរូបកាយដែលតែងតែស្លាប់នេះ បានប្រដាប់ដោយសេចក្តីមិនចេះស្លាប់វិញ នោះទើបនឹងបានសំរេចតាមពាក្យ ដែលចែងទុកមកថា «សេចក្តីជ័យជំនះបានលេបសេចក្តីស្លាប់បាត់ហើយ»។ «ឱសេចក្តីស្លាប់អើយ ទ្រនិចឯងនៅឯណា សេចក្តីស្លាប់អើយ ជ័យជំនះរបស់ឯងនៅឯណា»។ រីឯទ្រនិចនៃសេចក្តីស្លាប់ គឺជាអំពើបាប ហើយអំណាចរបស់បាប គឺជាក្រឹត្យវិន័យ។ តែអរព្រះគុណដល់ព្រះអង្គ ពីព្រោះទ្រង់ប្រទានឲ្យយើងរាល់គ្នាមានជ័យជំនះ ដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង(១កូរិនថូស ១៥:២៦,៥៤-៥៧)។

អ្នកជឿព្រះគ្រីស្ទអាចរស់នៅ និងស្លាប់ ដោយមានក្តីសង្ឃឹម ព្រោះព្រះអង្គបានឈ្នះសត្រូវធំបំផុតរបស់យើងហើយ។ ព្រះគ្រីស្ទបានដកទ្រនិចនៃសេចក្តីស្លាប់ចេញ ដោយដកចេញការភ័យខ្លាច ចំពោះការអ្វីដែលនឹងកើតឡើង បន្ទាប់ពីយើងស្លាប់

ទៅ។ ឥឡូវនេះ យើងអាចប្រឈមមុខដាក់សេចក្ដីស្លាប់ ដោយក្ដីសង្ឃឹមពិតប្រាកដ គឺមិនមែនសង្ឃឹម ដោយគ្រាន់តែប្រាថ្នាចង់បាន និងមានតែសម្បកក្រៅនោះឡើយ។

**ទស្សនៈអំពីការរស់ឡើងវិញផ្ទាល់ខ្លួន។** ការសង្ឃឹមថា យើងនឹងបានរស់ឡើងវិញ នាំឲ្យយើងផ្លាស់ប្តូរទស្សនៈរបស់យើង តាមរបៀបពីរយ៉ាង។

***ទីមួយ ការសង្ឃឹមថា នឹងបានរស់ឡើងវិញ មានផលប៉ះពាល់មកលើការគិតរបស់យើង អំពីជីវិត និងសេចក្ដីស្លាប់។*** បញ្ហានេះកើតឡើង ពេលដែលយើងជួបប្រទះការសោកសង្រេង ដោយសារការបាត់បង់មនុស្សជាទីស្រឡាញ់ ដែលបានស្លាប់។ សាវ័កប៉ុលក៏បានដឹងផងដែរថា កូនរបស់ព្រះក៏ចេះសោកសង្រេងផងដែរ។ ការបាត់បង់ គឺជាការបាត់បង់! យើងឈឺចាប់ ពេលដែលទំនាក់ទំនងរបស់យើង ត្រូវបានបំបែក ដោយសារសេចក្ដីស្លាប់ ដែលជាសត្រូវរបស់យើង។ ប៉ុន្តែ ក្នុងពេលដែលមានការឈឺចាប់ និងការបាត់បង់ សាវ័កប៉ុលបានរំឭកយើងថា ក្នុងនាមយើងជាអ្នកដើរតាមព្រះគ្រីស្ទ យើងមានអ្វីដែលខុសពីអ្នកមិនជឿ។ គឺដូចដែលគាត់បានសរសេរថា "បងប្អូនអើយ ខ្ញុំមិនចង់ឲ្យអ្នករាល់គ្នាឥតដឹង ពីពួកអ្នកដែលដេកលក់ទៅហើយទេ ក្រែងអ្នករាល់គ្នាកើតទុក្ខព្រួយ ដូចជាអ្នកឯទៀត ដែលគ្មានសង្ឃឹម"(១ថែស្សាឡូនិច ៤:១៣)។

នៅសតវត្សរ៍ទី១ ខណៈពេលដែលគោលទ្ធិរបស់គ្រីស្ទបរិស័ទបានចេញជារូបរាង អ្នកជឿព្រះនៅទីក្រុងថែស្សាឡូនិច មានសំណួរមួយចំនួន។ ហើយសំណួរដែលគួរឲ្យចាប់អារម្មណ៍ជាងគេគឺ តើនឹងមានអ្វីកើតឡើង ចំពោះមនុស្សជាទីស្រឡាញ់របស់យើង បន្ទាប់ពីពួកគេបានស្លាប់?

សាវ័កប៉ុលបានឆ្លើយតបសំណួរនេះ ក្នុងខ.១៤-១៨ ថា យើងអាចមានការកម្សាន្តចិត្ត ចំពោះព្រះបន្ទូលសន្យា អំពីការជួបជុំគ្នាឡើងវិញ នៅពេលអនាគតដែលនឹងមិនចេះចប់ឡើយ។ ទំនាក់ទំនងរបស់យើងប្រហែលជាត្រូវបានរំខានដោយសារសេចក្ដីស្លាប់ នៅលើផែនដី ប៉ុន្តែ នេះមិនមែនជាជំពូកចុងក្រោយ នៃជីវិតយើងឡើយ។ យើងនៅតែមានការឈឺចាប់ ដោយសារការបាត់បង់ ប៉ុន្តែ យើងមិនត្រូវឲ្យវាស៊ីបំផ្លាញយើងឡើយ។ យើងសោកសង្រេង តែមិនដូច "អ្នកដែលគ្មានសង្ឃឹមនោះឡើយ"។

ជ័យជម្នះរបស់ព្រះគ្រីស្ទមកលើសេចក្ដីស្លាប់បាននាំមកនូវក្ដីសង្ឃឹម ដែលមិនគ្រាន់តែបាននាំឲ្យយើងមានទំនុកចិត្ត ខណៈពេលដែលយើងប្រឈមមុខដាក់សេច

ក្តីស្លាប់ប៉ុណ្ណោះឡើយ តែក៏បានផ្តល់ឲ្យយើងនូវការរំពឹងចង់បានដ៏មានអំណរ នូវការជួបជុំគ្នាឡើងវិញក្នុងព្រះគ្រីស្ទ ខណៈពេលដែលយើងកំពុងតែអត់ទ្រាំនឹងការបាត់បង់មនុស្សជាទីស្រឡាញ់ដែលបានទទួលសេចក្តីសង្គ្រោះហើយ។ ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ បានផ្តល់ឲ្យយើងនូវក្តីសង្ឃឹម ខណៈពេលដែលយើងជួបការសោកសង្រេង និងទុក្ខព្រួយ ក្នុង "ជ្រលងនៃម្លប់នៃសេចក្តីស្លាប់"។

***ទីពីរ : ក្តីសង្ឃឹមថា នឹងរស់ឡើងវិញ នាំឲ្យយើងមានកម្លាំង និងភាពរស់រវើក នៅក្នុងការរស់នៅជាគ្រីស្ទបរិស័ទ។*** ជីវិតរបស់យើងនៅលើផែនដី គឺមិនគ្រាន់តែជួបអ្វីដែលកើតឡើង ខណៈពេលដែលយើងកំពុងរស់នៅនោះឡើយ។ តែយើងក៏ត្រូវរៀបចំខ្លួន សម្រាប់ភាពអស់កល្បជានិច្ចផងដែរ។ គឺដូចដែលសាវ័កប៉ុលបានសរសេរថា "បើសិនជាយើងមានទីសង្ឃឹមក្នុងព្រះគ្រីស្ទ នៅតែក្នុងជីវិតនេះប៉ុណ្ណោះ នោះយើងវេទនា លើសជាងមនុស្សទាំងអស់ទៅទៀត"(១កូរិនថូស ១៥:១៩)។

ខ្ញុំធ្លាប់ឮគេនិយាយថា ជីវិតដែលដើរតាមព្រះគ្រីស្ទ គឺជាជីវិតដែលប្រសើរបំផុត ទោះនរគស្ថានសួគ៌មានពិតមែន ឬមិនមានក៏ដោយ។ ជាការពិតណាស់ សាវ័កប៉ុលមិនយល់ស្របចំពោះមតិនេះឡើយ។ តាមការបង្រៀនរបស់គាត់ បើសិនជាគ្មានស្ថានសួគ៌ទេ នោះគ្រីស្ទបរិស័ទជាមនុស្សដែលគួរឲ្យអាណិតណាស់។ ហេតុអ្វី? ព្រោះពួកគេត្រូវមានពេលអនាគត សម្រាប់សម្លឹងឆ្ពោះទៅរកដោយសង្ឃឹម។ ពុំនោះទេ យើងត្រូវបានគេបោកប្រាស់ហើយ។

ប៉ុន្តែ ជីវិតយើងមិនមែនសម្រាប់រស់នៅ តែនៅលើផែនដីនោះឡើយ។ ផ្ទុយទៅវិញ បើយើងត្រូវរស់នៅឲ្យមានប្រសិទ្ធភាព ថ្វាយព្រះគ្រីស្ទ យើងត្រូវមានក្តីសង្ឃឹមទៅលើព្រះបន្ទូលសន្យា នូវជីវិតអស់កល្ប។ ដូចនេះ ក្តីសង្ឃឹមនេះ ដែលបានចាក់គ្រឹះនៅក្នុងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទ នឹងកែប្រែរបៀបនៃការរស់នៅរបស់យើងនៅលើផែនដី ព្រោះក្តីសង្ឃឹមនេះបាននាំឲ្យយើងមានទស្សនៈអំពីពេលអនាគត។

បានសេចក្តីថា ការមានព្រះជន្មរស់ឡើងវិញ បានផ្តល់ឲ្យយើងនូវការជានាដ៏អស្ចារ្យ។ ព្រះគ្រីស្ទបានឈ្នះសត្រូវធំបំផុតរបស់យើង ហើយទ្រង់ក៏អាចជួយយើង ឲ្យប្រឈមមុខដាក់ទុក្ខលំបាក និងបញ្ហាប្រឈមទាំងអស់ ក្នុងជីវិត។



**ទី៦**

# ក្តីសង្ឃឹមដ៏ស្ថិតស្ថេរ

អ្នកស្រីភើល បាក់(Pearl Buck) បានសរសេរថា "ការញ៉ាំនំប៉័ងដោយគ្មានសង្ឃឹម គឺជាការដាច់ពោះស្លាប់យឺតៗ"។ ប៉ុន្តែ គ្មាននរណាម្នាក់ ដែលគួរតែស្រេកឃ្លាន ដល់ស្លាប់នោះឡើយ។ ពេលណាគេចូលមករកព្រះគ្រីស្ទ គេអាចទទួលការអត់ទោសបាប ជីវិត និងទំនាក់ទំនងជាមួយព្រះជាម្ចាស់។

***អ្នកស្រីភើល អេស បាក់(ឆ្នាំ ១៨៩២ ដល់ ១៩៧៣)*** *គឺជាជនជាតិអាមេរិក ដែលជាអ្នកនិពន្ធរឿងប្រលោមលោក និងជាអ្នកធ្វើការមនុស្សធម៌ ដែលបាននិពន្ធសៀវភៅ ដែលមានចំណងជើងថា ផែនដីល្អ និងផ្ទះដែលមានការបាក់បែកគ្នា។ គាត់បានទទួលពានរង្វាន់ Pulitzer និងពានរង្វាន់ណូបែល សម្រាប់ផ្នែកអក្សរសាស្ត្រ។ គាត់បានទទួលការចិញ្ចឹមបីបាច់ពីបេសកជននិកាយសភាគិបាល ហើយធ្វើនូវកិច្ចការជាច្រើន ដើម្បីវាយបំបាក់រនាំងនៃការប្រកាន់ពូជសាសន៍ក្នុងសង្គម។*

សាវ័កប៉ុលបានសរសេរថា "ព្រះទ្រង់បានសព្វព្រះហឫទ័យ នឹងសំដែងឲ្យពួកបរិសុទ្ធនោះដឹងថា សិរីល្អដ៏បរិបូររបស់សេចក្តីអាថ៌កំបាំងនេះជាយ៉ាងណា ក្នុងពួកសាសន៍ដទៃ"(កូល៉ុស ១:២៧)។

ក្តីសង្ឃឹមនេះ ជាក្តីសង្ឃឹមថា នឹងបានសិរីល្អ ព្រោះយើងជារាស្ត្ររបស់ព្រះអង្គ ហើយព្រះអង្គជាព្រះរបស់យើង។ នៅក្នុងសុវត្ថិភាពនៃទំនាក់ទំនងនេះ ព្រះអង្គបាន

ប្រទានក្តីសង្ឃឹម ដែលបានចាក់ឫសចូលទៅក្នុងភាពពិត នៃជីវិតអស់កល្ប ដើម្បីឲ្យយើងអាចប្រឈមមុខដាក់ជីវិត តាមរបៀបដែលថ្វាយសិរីល្អដល់ព្រះអង្គ និងជួយយើង។

សូមយើងពិចារណា អំពីមូលហេតុដែលព្រះអង្គបានយាងមក :

តែកាលសេចក្តីសប្បុរស របស់ព្រះដ៏ជាព្រះអង្គសង្គ្រោះនៃយើង និងសេចក្តីស្រឡាញ់ របស់ទ្រង់ដល់មនុស្ស បានលេចមកឲ្យឃើញ នោះទ្រង់បានជួយសង្គ្រោះយើង មិនមែនដោយការដែលយើងបានប្រព្រឹត្តដោយសុចរិតនោះទេ គឺដោយសេចក្តីមេត្តាករុណារបស់ទ្រង់វិញ ដោយសារការសំអាតនៃសេចក្តីកើតជាថ្មី ហើយការប្រោសជាថ្មីឡើងវិញ នៃព្រះវិញ្ញាណបរិសុទ្ធ ដែលទ្រង់បានចាក់មកលើយើងជាបរិបូរ ដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃយើង ដើម្បីកាលណាយើងបានរាប់ជាសុចរិត ដោយសារព្រះគុណទ្រង់ នោះឲ្យយើងបានត្រឡប់ជាអ្នកគ្រងមរដក តាមសេចក្តីសង្ឃឹមដល់ជីវិតដ៏នៅអស់កល្បជានិច្ច(ទីតុស ៣:៤-៧)។

គឺដោយសារសេចក្តីសប្បុរស និងសេចក្តីស្រឡាញ់របស់ព្រះ បានជាព្រះអង្គបានចាត់ព្រះគ្រីស្ទឲ្យមកសង្គ្រោះយើង ឲ្យរួចពីបាប និងឲ្យរួចពីខ្លួនយើង ដើម្បីឲ្យយើងអាច "សង្ឃឹមថាបានជីវិតអស់កល្ប" (ខ.៧)។



បើអ្នកបានស្គាល់ព្រះគ្រីស្ទ ហើយ តើបានស្គាល់ក្តីសង្ឃឹមរបស់ទ្រង់ច្បាស់ប៉ុណ្ណា?

អ្នកអាចទទួលសេចក្តីសន្យានេះ ដោយងាកបែរទៅរកព្រះគ្រីស្ទ ដោយសារភាពអំពើបាប និងកំហុសរបស់អ្នក ហើយទទួលយកការអត់ទោសបាបពីព្រះអង្គ និងក្តីសង្ឃឹម ដែលនៅជាប់នឹងការអត់ទោសបាបនោះ។ នេះជាព្រះបន្ទូលសន្យា ដល់អ្នករាល់គ្នា ... "ដែលដោយសារទ្រង់ នោះអ្នករាល់គ្នាក៏ជឿដល់ព្រះដែលប្រោសឲ្យទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញ ព្រមទាំងប្រទានឲ្យមានសិរីល្អ ដើម្បីឲ្យសេចក្តីជំនឿ ហើយនិងសេចក្តីសង្ឃឹមរបស់អ្នករាល់គ្នាបានជាប់នៅនឹងព្រះ"(១ពេត្រុស ១:២១)។

បើអ្នកបានស្គាល់ព្រះគ្រីស្ទហើយ តើបានស្គាល់ក្តីសង្ឃឹមរបស់ទ្រង់ច្បាស់ប៉ុណ្ណា? ក្តីសង្ឃឹមរបស់ទ្រង់ គឺជាការពិតដ៏អស្ចារ្យ និងពេញដោយព្រះគុណ ហើយ

ក៏កែប្រែជីវិត ដែលជួយឲ្យយើងអាចមើលឃើញជីវិតតាមទស្សនៈខុសពីមុន។ ត្រង់ចំណុចនេះ សាវ័កប៉ុលបានសរសេរថា "ដ្បិតយើងបានសង្គ្រោះរួច ដោយសេចក្ដីសង្ឃឹម តែសេចក្ដីសង្ឃឹមដែលមើលឃើញ នោះមិនឈ្មោះថាជាសេចក្ដីសង្ឃឹមទេ ដ្បិតរបស់អ្វីដែលអ្នកណាមើលឃើញហើយ នោះនឹងសង្ឃឹមចង់បានធ្វើអ្វីទៀត។ តែបើយើងសង្ឃឹមនឹងបានអ្វី ដែលមើលមិនឃើញវិញ នោះយើងនឹងរង់ចាំនៅដោយអំណត់"(រ៉ូម ៨:២៤-២៥)។

មានពេលខ្លះ ក្ដីសង្ឃឹមហាក់ដូចជាការរវើរវាយ ប៉ុន្តែ យើងតែងតែអាចទុកចិត្តព្រះនៃសេចក្ដីសង្ឃឹម។ ព្រះអង្គគង់នៅជាមួយយើងជានិច្ច ហើយសេចក្ដីមេត្តា ដែលព្រះអង្គ មានចំពោះយើងក៏ស្ថិតស្ថេរជាដរាប។



*យើងអាចស៊ូទ្រាំ ដោយការរំពឹងចង់បាន ដោយទំនុកចិត្តថា យើងមិននៅឯកោ ឬត្រូវបានព្រះអម្ចាស់បំភ្លេចនោះឡើយ។ ព្រះអង្គនឹងមិនបោះបង់*

## ក្ដីសង្ឃឹមក្លាយជាការពិត ការភ័យខ្លាចរលាយ

ខណៈពេលដែលពួកកូនចៅអ៊ីស្រាអែលមានការភ័យញាប់ញ័រ នៅឆ្នេរសមុទ្រក្រហម លោកម៉ូសេក៏បានប្រាប់ពួកគេថា "កុំខ្លាចអី ឈប់សិន ចាំមើលសេចក្ដីសង្គ្រោះរបស់ព្រះយេហូវ៉ា ដែលទ្រង់នឹងប្រោសដល់អ្នករាល់គ្នានៅថ្ងៃនេះ"(និក្ខមនំ ១៤:១៣)។ ព្រះជាម្ចាស់ក៏បានឲ្យ "ខ្យល់បក់បោកយ៉ាងខ្លាំងពីទិសខាងកើត" ដើម្បីញែកទឹកសមុទ្រជាពីរ បង្កើតជាផ្លូវស្ងួតដើរកាត់សមុទ្រ។ ពួកអ៊ីស្រាអែលក៏បានគេចផុតពីគ្រោះថ្នាក់ នៅពេលនោះ ហើយកងទ័ពរបស់សាសន៍អេស៊ីព្ទក៏បានលង់ទឹក នៅក្នុងការដេញតាមពួកគេ។

យើងអាចស៊ូទ្រាំ ដោយការរំពឹងចង់បាន ដោយទំនុកចិត្តថា យើងមិននៅឯកោ ឬត្រូវបានព្រះអម្ចាស់បំភ្លេចនោះឡើយ។ ព្រះអង្គនឹងមិនបោះបង់យើងចោលឡើយ។ បទគម្ពីរនិក្ខមនំ ជំពូក១៥ ជាទំនុកនៃជ័យជម្នះ ដែលច្រៀងសរសើរព្រះ សម្រាប់ការរំដោះរាស្ត្រព្រះអង្គ ដោយការអស្ចារ្យរបស់ព្រះអង្គ នៅចំពោះមុខនៃបញ្ហាដែលហាក់ដូចជាមិនអាចឆ្លងកាត់រួច។

***បទចម្រៀងសរសើរដំកើងរបស់លោកម៉ូសេ*** *ក្នុងបទគម្ពីរនិក្ខមនំ ១៥:១-១៨ មិនគ្រាន់តែបានរំឭក អំពីការរំដោះរបស់ព្រះជាម្ចាស់ប៉ុណ្ណោះទេ តែថែមទាំងបានសម្លឹងឆ្ពោះមុខ* ***ដោយការរំពឹងរង់ចាំ ដោយសង្ឃឹម*** *ទៅរកការចូលកាន់កាប់ទឹកដីសន្យា(ខ.១៤-១៧)។ ក្ដីសង្ឃឹមដែលបានសម្រេចក្នុងពេលបច្ចុប្បន្ន និងអតីតកាល នាំមកនូវអត្ថន័យកាន់តែជ្រាលជ្រៅ ដល់ក្ដីសង្ឃឹម សម្រាប់ពេលអនាគត។*

នៅចំពោះមុខនៃកាលៈទេសៈពិបាកបំផុតនៃជីវិត និងសោកនាដកម្មអាក្រក់បំផុត យើងអាចទុកចិត្តព្រះអម្ចាស់។ យើងអាចស៊ូទ្រាំ ក្នុងការរំពឹងដោយទំនុកចិត្តថា យើងមិននៅឯកោ ឬត្រូវបានបំភ្លេចនោះឡើយ។ ព្រះអង្គនឹងមិនបោះបង់យើងចោលឡើយ។

ព្រះគ្រីស្ទបានមានព្រះជន្មរស់ឡើងវិញហើយ! ព្រះនៃសេចក្ដីសង្ឃឹម យើងហៅព្រះអង្គថា ព្រះវរបិតាដែលគង់នៅស្ថានសួគ៌។

# ក្រុមសៀវភៅការរុករកឃើញ

*ការងារបេសកកម្មរបស់យើងខ្ញុំ គឺដើម្បីឲ្យមនុស្សគ្រប់រូប មានឱកាសទទួល និងមានការយល់ដឹងអំពីប្រាជ្ញានៃព្រះគម្ពីរ ដែលធ្វើឲ្យជីវិតផ្លាស់ប្រែ ។*

ក្រុមសៀវភៅការរុករកឃើញ បកស្រាយអំពីសេចក្ដីពិតនៃព្រះយេស៊ូវគ្រីស្ទ ដល់លោកិយ ដោយប្រើធនធានដែលមានគុណភាព ដែលគួរឲ្យចាប់អារម្មណ៍ និងអាចរកបាន ដែលបង្ហាញថា ព្រះគម្ពីរមានសារៈសំខាន់បំផុត ចំពោះគ្រប់ផ្នែកទាំងអស់នៃជីវិត។ កូនសៀវភៅ នៅក្នុងក្រុមសៀវភៅការរុករកឃើញ គឺអាចរកបាន ដោយឥតគិតថ្លៃ ហើយអាចត្រូវបានប្រើសម្រាប់ការសិក្សាផ្ទាល់ខ្លួន ក្នុងក្រុមតូច ឬក្នុងការងារឈោងចាប់។

យើងខ្ញុំសូមអរគុណ សម្រាប់ការគាំទ្រធនធានរបស់ក្រុមសៀវភៅការរុករកឃើញ និងអង្គការនំម៉ាណាប្រចាំថ្ងៃ។ មានគ្រីស្ទបរិស័ទជាច្រើនបានរួមចំណែកក្នុងការដាក់ដង្វាយឧបត្ថម្ភ ទោះតិចតួច ឬច្រើនក្ដី ដល់អង្គការនំម៉ាណាប្រចាំថ្ងៃ ដើម្បីឲ្យឈោងចាប់អ្នកដទៃ ដោយប្រាជ្ញានៃព្រះគម្ពីរដែលធ្វើឲ្យជីវិតផ្លាស់ប្រែ។ យើងខ្ញុំមិនបានទទួលប្រាក់ជំនួយពីក្រុម ឬនិកាយណាមួយឡើយ។

CLICK TO DONATE